**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Feb-2016, 15:51
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (កោសលុប)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើបន្ទាន់ និង រួមគ្នា របស់ នួន ជា សុំឲ្យពន្លឿនសំណើពីររបស់ខ្លួនដែលបានស្នើរួចហើយ និងសុំឲ្យកោះហៅសាក្សីបន្ថែមបួនរូប ពាក់ព័ន្ធការប្រព្រឹត្តិចំពោះជនជាតិចាម**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

ព្រុំ ផល្លា

Doreen CHEN
Xiaoyang NIE
Marina HAKKOU
Henri DECOEUR

**ចម្លងជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**សហព្រះរាជអាជ្ញា÷**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨៧(៤) និងវិធាន ៩១ នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីលោក នួន ជា (“មេធាវីការពារក្តី”) សូមដាក់សំណើបន្ទាន់ និង រួមគ្នា សុំស្តាប់សាក្សីបន្ថែមចំនួនប្រាំមួយ ក្នុងអំឡុងពេលសវនាការលើការប្រព្រឹត្តិចំពោះជនជាតិចាម (“សំណើ”)។ សាក្សីដែលបានស្នើចំនួនប្រាំមួយនាក់នេះ គឺជាអតីតកម្មាភិបាលដែលមានតួនាទីខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលអាចផ្តល់ព័ត៌មានលម្អិតដែលសំខាន់ និងមិនមានអ្វីជំនួសបាន អំពីហេតុការណ៍ វចនាសម្ព័ន្ធ ការសម្រេច និងគោលនយោបាយនៅក្នុងតំបន់ ២១ នៃភូមិភាគបូព៌ា៖ ទីតាំងមួយក្នុងចំណោមទីតាំងទាំងពីរ ដែលមាននៅក្នុងវិសាលភាពសំណុំរឿង ០០២/០២ ដែលឧក្រិដ្ឋកម្មប្រឆាំងជនជាតិចាម ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើង។ សាក្សីពីរនាក់ដំបូងគឺ [redacted][1] និង [redacted][2] ដែលមេធាវីការពារក្តីបានស្នើសុំរួចហើយ ឲ្យមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២[3] ហើយដែលក្នុងពេលបច្ចុប្បន្ន កំពុងស្វែងរកការកំណត់កាលបរិច្ឆេទ ដោយផ្អែកលើមូលដ្ឋាននៃភាពឆាប់រហ័ស។ សាក្សីទីបីគឺ ហ៊ុន សែន[4] ដែលមេធាវីការពារក្តីបានស្នើសុំកន្លងមកក្នុងសំណុំរឿង ០០២[5] តែត្រូវបានដកចេញពីបញ្ជីសាក្សី របស់មេធាវីការពារក្តីវិញ ក្នុងសំណុំរឿង ០០២/០២ ហើយក្នុងសំណើបច្ចុប្បន្ននេះត្រូវបានស្នើសុំជាថ្មី។ សាក្សីទីបួន ទីប្រាំ និងទីប្រាំមួយ គឺជាសាក្សីថ្មីដែលមិនត្រូវបានស្នើសុំនាពេលកន្លងមកទេ។ សាក្សីមួយរូបគឺជាអតីតកងទ័ព មកពីកងវរសេនាតូចលេខ ៥៥ នៃភូមិភាគបូព៌ា, មួយរូបទៀតគឺជាកូនប្រុសរបស់[redacted] និងសាក្សីចុងក្រោយគឺកូនស្រីរបស់

---

[1] [redacted]។ រហស្សនាមរបស់គាត់ក្នុងសំណុំរឿង ០០២/០២ គឺ 2-TCW-831។

[2] រហស្សនាមរបស់ [redacted]។ រហស្សនាមរបស់គាត់ក្នុងសំណុំរឿង ០០២/០២ គឺ 2-TCW-951។

[3] ឯកសារ **E305/4**, ‘បញ្ជីឈ្មោះ និងព័ត៌មានសង្ខេបដែលបានធ្វើបច្ចុប្បន្នភាព ស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើសុំ’, ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ (“បញ្ជីឈ្មោះសាក្សី សំណុំរឿង ០០២/០២”)។ ឯកសារ **E305/4.1**, ‘ឧបសម្ព័ន្ធ ក៖ បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានធ្វើបច្ចុប្បន្នភាព (ដែលមិនស្នើសុំវិធានការការពារ)’, #9 និង #22។

[4] រហស្សនាមរបស់ ហ៊ុន សែន ក្នុងសំណុំរឿង ០០២ គឺ TCW-248។

[5] ឯកសារ **E9/4/4**, ‘បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើសុំ’, ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ (“បញ្ជីឈ្មោះសាក្សីដើម សំណុំរឿង ០០២”)។

សោ ភឹម លេខាភូមិភាគបូព៌ា។

## II. ប្រវត្តិនីតិវិធី និងសាវតា

### ក. សំណើរបស់មេធាវីការពារក្តី ស្នើសុំសាក្សីក្នុងសំណុំរឿង ០០២

2. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តីបានដាក់បញ្ជីស្នើសុំសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ក្នុងសំណុំរឿង ០០២ លើកទីមួយរបស់ខ្លួន ("បញ្ជីឈ្មោះសាក្សីដើមក្នុងសំណុំរឿង០០២")។ នៅក្នុងបញ្ជីនេះមេធាវីការពារក្តី បានស្នើសុំសក្ខីកម្មរបស់សមាជិករដ្ឋាភិបាល និងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ជាច្រើនរូប ដែលជាអតីតកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជានៅភូមិភាគបូព៌ា ដែលអាចផ្តល់សក្ខីកម្មលើអង្គហេតុសំខាន់ៗ ចំពោះបញ្ហាដែលត្រូវបានជំទាស់ជាច្រើនដង នៅក្នុងសំណុំរឿង ០០២។ អ្នកទាំងនោះរួមមាន [redacted], [redacted], ហ៊ុន សែន, និងជា ស៊ីម[6]។ ក្នុងអំឡុងសវនាការលើសំណុំរឿង ០០២/០១ មេធាវីការពារក្តីបានស្នើសុំ ឱ្យកោះហៅសាក្សីទាំងអស់នេះ ជាច្រើនលើកច្រើនគ្រា ជាពិសេសគឺ [redacted][7]។

3. គ្មានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងនេះ បានមកបង្ហាញខ្លួននៅក្នុងសំណុំរឿង ០០២/០១ ឡើយ។ សេចក្តីសម្រេចស្តាពរថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ របស់អង្គជំនុំជម្រះសាលាដំបូង អំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ("សេចក្តីសម្រេចស្តាពរស្តីពីសាក្សីសំណុំរឿង ០០២/០១")[8] បានបង្ហាញអំពីមូលហេតុនេះ។ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានបដិសេធជាឯកច្ឆន្ទ មិនកោះហៅ ជា ស៊ីម និង ហ៊ុន សែន

---

[6] ឯកសារ [redacted]។

[7] ត្រង់ចំណុចនេះ, [redacted]។

[8] ឯកសារ **E312**, 'សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១', ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចស្តាពរស្តីពីសាក្សី ក្នុងសំណុំរឿង ០០២/០១")។

ដោយផ្អែកលើមូលដ្ឋានថា សក្ខីកម្មរបស់ពួកគេគឺ "មិនមានភាពពាក់ព័ន្ធ"[9]។ ប៉ុន្តែចៅក្រមអង្គជំនុំជម្រះសាលាដំបូង "មិនអាចឈានដល់ការឯកភាពរួមគ្នា" លើការកោះហៅ [redacted] និង [redacted][10]។ ចៅក្រមជាតិទាំងបីរូបមិនកោះហៅពួកគេណាមួយឡើយ។ ចៅក្រមទាំងនេះបានអះអាងថា សក្ខីកម្មរបស់សាក្សីទាំងនេះ មានភាពច្រំដែល ហើយ "មានភាពពាក់ព័ន្ធតិចតួច" ក្នុងករណី [redacted] និង "មិនមានភាពពាក់ព័ន្ធ" ក្នុងករណី [redacted][11]។ បន្ថែមលើនេះ ចៅក្រមជាតិបានកត់សម្គាល់អំពី "ការលំបាកជាក់ស្តែងនៃការអនុវត្តដីកាបែបនេះ តម្រូវឲ្យយើងមិនកោះហៅបុគ្គលទាំងនេះ"[12]។ ប៉ុន្តែចៅក្រមអន្តរជាតិពីររូប នឹងធ្វើការកោះហៅ សាក្សីទាំងពីររូប[13] ដោយកត់សម្គាល់ផ្ទុយថា សាក្សីទាំងពីររូប "ហាក់ដូចជាដឹងអំពីព័ត៌មាន ដែលសាក្សីដែលត្រូវបានស្នើសុំផ្សេងទៀត មិនអាចបានដឹងព័ត៌មាននេះ ក្នុងសំណុំរឿង ០០២/០១"[14] ហើយបានសន្និដ្ឋានថា សក្ខីកម្មរបស់គាត់ "មានភាពពាក់ព័ន្ធ ហើយអាចជួយដល់អង្គជំនុំជម្រះ ក្នុងការស្វែងរកការពិត"[15]។ ចៅក្រមអន្តរជាតិក៏បានសង្កត់ធ្ងន់ផងដែរថា "ក្នុងនាមជាប្រជាពលរដ្ឋ គាត់មានភារកិច្ចជួយចៅក្រម អ.វ.ត.ក ក្នុងការស្វែងរកការពិតក្នុងសំណុំរឿងមួយ ដែលមានសារសំខាន់ជាសារវន្តចំពោះប្រជាជនកម្ពុជា"[16]។

4. ភាពខុសគ្នាលើជំហររបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានរារាំងសេចក្តីសម្រេច កោះហៅ [redacted] ឬ [redacted] ដែលមិនមាននរណាម្នាក់ ត្រូវបានកោះហៅមកផ្តល់សក្ខីកម្មក្នុង

---

[9] អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សក្ខីកម្មរបស់ ជា ស៊ីម គឺ "មានភាពពាក់ព័ន្ធតិចតួច" ហើយនឹងជា "ភស្តុតាងច្រំដែលជាមួយភស្តុតាងដែលមានរួចហើយ នៅចំពោះមុខអង្គជំនុំជម្រះ" ក្នុងសំណុំរឿង ០០២/០១៖ ឯកសារ **E312**, សេចក្តីសម្រេចស្តាពរស្តីពីសាក្សី ក្នុងសំណុំរឿង ០០២/០១, កថាខណ្ឌ ៦៩។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា សំណើសុំកោះហៅ ហ៊ុន សែន "មិនបានបំពេញតាមលក្ខខណ្ឌតម្រូវ នៃភាពពាក់ព័ន្ធ"៖ ឯកសារ **E312**, សេចក្តីសម្រេចស្តាពរស្តីពីសាក្សី ក្នុងសំណុំរឿង ០០២/០១, កថាខណ្ឌ ១២៥។

[10] [redacted]

[11] [redacted]។

[12] [redacted]

[13] [redacted]

[14] [redacted]

[15] [redacted]

[16] [redacted]

សំណុំរឿង០០២/០១ឡើយ។ ការបែងចែកគ្នារវាងគោលជំហរ ចៅក្រមជាតិនិងចៅក្រមអន្តរជាតិ នេះ បានផ្ទុះបញ្ច្រាំងពីការបែងចែកគ្នា ដែលក្នុងពេលកន្លងមកបានកើតឡើង រវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏ដូចជារវាងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ នៃអង្គបុរេជំនុំជម្រះ ព្រមទាំងរវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលបន្តវេន[17] ចំពោះបញ្ហាតែមួយដូចគ្នានេះ[18]។ ការបែងចែងយ៉ាងច្បាស់ និងបន្តបន្ទាប់រវាងចៅក្រមជាតិ និងអន្តរជាតិ គឺជាមូលហេតុធ្វើឲ្យមេធាវីការពារក្តីដាក់បណ្តឹងដិតចិត្តមួយកាលពីមួយឆ្នាំមុនគិតមកដល់ថ្ងៃនេះ គឺនៅថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ដើម្បីសុំដកចៅក្រម និល ណុន យ៉ា សុខន Jean-Marc Lavergne និង យូ ឧត្តរា ចេញពីសំណុំរឿង ០០២/០២ (“សំណើដិតចិត្តលើកទីពីរ”)។ នៅក្នុងសំណើនោះមេធាវីការពារក្តីបានអះអាងថា ដោយពិចារណាទៅលើប្រវត្តិនីតិវិធីនេះ ភាពមិនចុះសម្រុងគ្នារបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចស្តាពរស្តីពីសាក្សីក្នុងការកោះហៅ [redacted] បញ្ជាក់អំពីអត្ថិភាពដែលចៅក្រមជាតិទាំងបីរូប គ្មាន “បង្ហាញឲ្យឃើញនូវឯករាជ្យភាព” ដើម្បីនៅជាចៅក្រមកាត់សេចក្តីលើសំណុំរឿង ០០២/០២ ទៀតនោះទេ[19]។ ស្រដៀងគ្នានេះដែរនៅសេចក្តីថ្លែងបើកក្នុងសំណុំរឿង ០០២/០២ នួន ជា បាននិយាយទៅកាន់ចៅក្រមជាតិថា “លោក លោកស្រីចៅក្រមទាំងអស់បានបង្ហាញកង្វះឯករាជ្យភាព

---

[17] ពាក់ព័ន្ធសហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley, សូមមើលជាឧទាហរណ៍, ឯកសារ **D314/1/5**, ‘ការកត់សម្គាល់របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះបណ្តឹងឧទ្ធរណ៍របស់ អៀង សារី និង នួន ជា ចំពោះការកោះហៅសាក្សីបន្ថែម’, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១០។ ពាក់ព័ន្ធសហព្រះរាជអាជ្ញាអន្តរជាតិ Nicholas Koumjian, សូមមើលផ្នែកខាងក្រោម, កថាខណ្ឌ **Error! Reference source not found.**។

[18] ពាក់ព័ន្ធសហចៅក្រមស៊ើបអង្កេត Lemonde, [redacted] និង ឯកសារ **E189/3/1/7.1.3**, ‘Un Juge Face aux Khmers Rouges’, ទំព័រ ១៧២ (in which Judge Lemonde referred to [redacted] as “*qu’il nous fallait absolument interroger*”, [redacted])។ ពាក់ព័ន្ធចៅក្រមអង្គបុរេជំនុំជម្រះ Downing និង Marchi-Uhel, សូមមើលជាឧទាហរណ៍, ឯកសារ **D314/1/12**, ‘សាលដីកាលើកទីពីរចំពោះបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង សារី ប្រឆាំងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំកោះហៅសាក្សី’, ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០។

[19] **E314/6** “បណ្តឹងដិតចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និង យូ ឧត្តរា” ថ្ងៃទី ២៩ កញ្ញា ឆ្នាំ២០១៤។ សូមមើលផងដែរ *Volkov v. Ukraine*, ‘Judgement’, ECtHR, App. No. 21722/11 ថ្ងៃទី២៧ ឧសភា ឆ្នាំ ២០១៣។

ក្នុងការសម្រេចមិនកោះហៅ [redacted]”[20]។ បន្ថែមលើបណ្តឹងជិតចិត្តទៅលើចៅក្រមទាំងបួនរបស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១។ នៅក្នុងសេចក្តីជូនដំណឹងនោះមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋាន២២៣ នៃបណ្តឹងឧទ្ធរណ៍គឺ “អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងបានរំលោភបំពានទៅលើសិទ្ធិរបស់ នួន ជា ក្នុងការការពារខ្លួនដោយបដិសេធមិនព្រមស្តាប់សក្ខីកម្មរបស់សាក្សីដោះបន្ទុកសំខាន់ៗដទៃទៀត រួមទាំង [redacted]”[21]។

5. នៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ជូននូវបញ្ជីឈ្មោះសាក្សីបឋមរបស់ខ្លួន សម្រាប់សំណុំរឿង ០០២/០២ (“បញ្ជីឈ្មោះសាក្សីសំណុំរឿង ០០២/០២” )។ យោងតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង[22] បញ្ជីនេះគឺជាបញ្ជីសាក្សីសំណុំរឿង ០០២ ដើម ដែលបានធ្វើបច្ចុប្បន្នភាពថ្មី។ នៅក្នុងបញ្ជីនេះ មេធាវីការពារក្តីបានសម្រេចរក្សាសំណើរបស់ខ្លួនសុំកោះហៅ [redacted], [redacted] និងជា ស៊ីម។ មេធាវីការពារក្តីសម្រេចដកឈ្មោះ ហ៊ុន សែន ចេញពីបញ្ជីសាក្សីដែលបានធ្វើបច្ចុប្បន្នភាព ដោយផ្អែកលើមូលដ្ឋានថា ការរក្សាសំណើរបស់ខ្លួនសុំឱ្យស្តាប់សក្ខីកម្មរបស់គាត់ នឹងមិនត្រូវបានពិចារណាឡើយ។ មេធាវីការពារក្តីក៏សង្ឃឹមផងដែរថា ការដកចេញឈ្មោះ ហ៊ុន សែន ពីក្នុងសំណើរបស់ខ្លួន ធ្វើឱ្យចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូង អាចនឹងយល់ព្រមឱ្យកោះហៅ [redacted] និង ជា ស៊ីម។ ប៉ុន្តែមិនមានសាក្សីណាម្នាក់ ក្នុងចំណោមសាក្សីទាំងនេះ ត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម ក្នុងសំណុំរឿង ០០២ នៅឡើយ ហើយនៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ជា ស៊ីម បានស្លាប់[23]។ នេះគឺជាភាព

---

20 [redacted]។

21 ឯកសារ E313/1/1 “សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១”ថ្ងៃទី២៩ ខែ កញ្ញាឆ្នាំ ២០១៤ [redacted]។

22 ឯកសារ E305, ‘ដីកាបង្គាប់ឱ្យដាក់ឯកសារដែលបានកែសម្រួលថ្មី ដើម្បីត្រៀមរៀបចំសវនាការ ក្នុងសំណុំរឿង ០០២/០២’, ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤, កថាខណ្ឌ ១។

23 Saing Soenthrith, ‘CPP President Chea Sim Dead’, សារព័ត៌មាន *Cambodia Daily*, ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥។

អកុសលជាពិសេស សម្រាប់គោលបំណងបច្ចុប្បន្ន ដោយសារតែ ជា ស៊ីម អាចផ្តល់នូវសក្ខីកម្មដ៏សំខាន់ សម្រាប់ការប្រព្រឹត្តិចំពោះជនជាតិចាម។ មុនពេលមរណភាព ជា ស៊ីម គឺ ជាសាក្សីផ្ទាល់ភ្នែក ដែលនៅរស់រានជីវិតម្នាក់ ក្នុងចំណោមសាក្សីផ្ទាល់ភ្នែកតែពីរនាក់គត់ (រួមជាមួយ [redacted]) ដែលអាចផ្តល់សក្ខីកម្មអំពីហេតុការណ៍ ក្នុងសន្និបាតរបស់បក្សកុម្មុយនីស្តកម្ពុជា នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ នាក្នុងទីក្រុងភ្នំពេញ។ សន្និបាតនេះគឺជាចំណុចសំខាន់ នៃការអះអាងទាំងនៅក្នុងដីកាដំណោះស្រាយ និងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ដែលថាមានគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅលើជនជាតិចាម ដែលទាំង ប៉ុល ពត និង នួន ជា ត្រូវទទួលខុសត្រូវដោយផ្ទាល់[24]។ បន្ថែមលើនេះ ជា ស៊ីម គឺជាសាក្សីតែម្នាក់គត់ ដែលសហព្រះរាជអាជ្ញាបានដកស្រង់ នៅក្នុងដីកាសន្និដ្ឋានស្ថាពរ ក្នុងការចោទប្រកាន់ថាបក្សកុម្មុយនីស្តកម្ពុជា មានចេតនាបំផ្លាញជនជាតិចាម ព្រោះ៖

> ប៉ុល ពតបានប្រាប់កម្មាភិបាលបក្សថា ចាម និងក្រុមជនជាតិភាគតិចដទៃទៀត ត្រូវតែ "សម្លាប់ចោលទាំងអស់"។ ការសម្លាប់ទាំងនេះបានកើតឡើងបន្តិចម្តងៗ ប៉ុន្តែត្រឹមឆ្នាំ ១៩៧៨ បានក្លាយជាការវាយប្រហារ "យ៉ាងសាហាវ"[25]។

6. នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាជាតិ ជា លាង បានដាក់ការជំទាស់របស់ខ្លួន ចំពោះបញ្ជីសាក្សីដែលបានធ្វើបច្ចុប្បន្នភាពហើយ។ គាត់បានជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី សុំកោះហៅសាក្សីចំនួនបីរូបគឺ [redacted] និង ជា ស៊ីម ដោយផ្អែកលើមូលដ្ឋានថា [redacted]

---

[24] ឯកសារ **D427**, 'ដីកាដំណោះស្រាយ', ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ"), កថាខណ្ឌ ៧៥៣។ ឯកសារ **D390**, 'សារណាបញ្ចប់ការពិភាក្សាដេញដោល របស់សហព្រះរាជអាជ្ញា តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង' ("សារណាបញ្ចប់ការពិភាក្សាដេញដោល របស់សហព្រះរាជអាជ្ញា"), ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០, កថាខណ្ឌ ៧៥៧។

[25] ឯកសារ **D390**, សារណាបញ្ចប់ការពិភាក្សាដេញដោល របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៧៧៤(១) (ជើងទំព័រត្រូវបានលុបចេញ)។ សូមមើលផងដែរ, ជើងទំព័រ ៣៨៥៣ និង ៣៨៥៤។

[26] ឯកសារ **E305/10**, 'ការជំទាស់របស់សហព្រះរាជអាជ្ញាជាតិ ចំពោះសាក្សី និងអ្នកជំនាញដែលត្រូវបានស្នើឡើងដោយភាគីដទៃ', ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤, កថាខណ្ឌ ៣។

[redacted]។ ផ្ទុយទៅវិញនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ នៅក្នុងសវនាការបឋមក្នុងសំណុំរឿង ០០២/០២ សហព្រះរាជអាជ្ញាអន្តរជាតិ Nicholas Koumjian បានព្យាយាមសង្កត់ធ្ងន់ថា "ត្រង់ចំនុចជាក់លាក់មួយនេះ ខ្ញុំមានគោលជំហរផ្សេង ហើយខ្ញុំមិនជំទាស់ចំពោះការស្នើសុំកោះហៅសាក្សីណាម្នាក់ ដែលបានស្នើឡើងដោយក្រុមមេធាវីការពារក្តី របស់ខៀវ សំផន ឬ នួន ជា ឡើយ"[28]។

7. ដោយពិចារណារួមជាមួយសំណើសុំកោះហៅសាក្សីរបស់ខ្លួន ដែលបានធ្វើឡើងក្នុងអំឡុងសវនាការលើសំណុំរឿង ០០២/០១ និងសំណើសុំកោះហៅសាក្សីសំណុំរឿង ០០២/០២ [redacted] របស់ខ្លួននោះ [redacted] របស់មេធាវីការពារក្តីសុំកោះហៅ [redacted] ឱ្យមកផ្តល់សក្ខីកម្មលើសំណុំរឿង ០០២ ទាំងស្រុង និងជាសំណើ [redacted] ហៅ [redacted]។ មេធាវីការពារក្តីក៏បានស្នើសុំផងដែរដល់អង្គជំនុំជម្រះតុលាការកំពូលឱ្យកំណត់កាលបរិច្ឆេទសម្រាប់សាក្សីទាំងពីរ មកផ្តល់សក្ខីកម្មពាក់ព័ន្ធបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១[29]។ មិនទាន់មានសេចក្តីសម្រេចណាមួយលើបញ្ហានេះនៅឡើយទេ។

## ខ. ប្រធានបទសវនាការសំណុំរឿង ០០២/០២ អំពីការប្រព្រឹត្តិចំពោះជនជាតិចាម

8. នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសសេចក្តីសម្រេចរបស់ខ្លួន ស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០២[30]។ អង្គជំនុំជម្រះបានដាក់បញ្ចូលនូវផ្នែកទាំងស្រុងចេញពីដីកាដំណោះស្រាយ ស្តីពីការប្រព្រឹត្តិចំពោះជនជាតិចាម ដោយអង្គជំនុំជម្រះបានជ្រើសរើសដកចេញពីវិសាលភាព នូវទីតាំងឧក្រិដ្ឋកម្មតែមួយប៉ុណ្ណោះ គឺមន្ទីរសន្តិសុខក្រូចឆ្មារ នៅក្នុងតំបន់

---

[27] ឯកសារ **E305/10** "ការជំទាស់របស់សហព្រះរាជអាជ្ញាជាតិទៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយភាគីដទៃ" ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ៣។

[28] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ (សវនាការបឋម សំណុំរឿង ០០២/០២, ឯកសារ **E1/240.1**), ទំព័រ ១១២, ជួរ ១៩ ដល់២២។

[29] ឯកសារ **F16**, 'បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងសាក្រមក្នុងសំណុំរឿង ០០២/០១', ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤, [redacted]។

[30] ឯកសារ **E301/9/1**, 'សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម ក្នុងសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២', ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤។

២១ ភូមិភាគបូព៌ា[31]។ អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុណាមួយ សម្រាប់ការដកចេញនេះឡើយ ហើយតាមពិតទៅមេធាវីការពារក្តី បានកត់សម្គាល់ជាច្រើនដងក្នុងពេលសវនាការលើសំណុំរឿង ០០២/០២ ដែលភស្តុតាងនៃមន្ទីរសន្តិសុខបន្ថែមហាក់ដូចជាមានភាពពាក់ព័ន្ធ ហើយត្រូវបានពិភាក្សាយ៉ាងលម្អិត បើទោះបីជាមន្ទីរសន្តិសុខទាំងនោះមិនត្រូវបានលើកឡើងនៅក្នុងដីកាដំណោះស្រាយក៏ដោយ (ឧទាហរណ៍ មន្ទីរ ២០៤ ឬព្រៃក្តួច ក្នុងស្រុកត្រាំកក់)។ មេធាវីការពារក្តីសន្មតថាមន្ទីរសន្តិសុខក្រូចឆ្មារ ត្រូវបានដកចេញដោយសារតែសហព្រះរាជអាជ្ញាបានស្នើសុំបែបនេះ នៅពេលធ្វើសារណាស្តីពីវិសាលភាព នៃសំណុំរឿង ០០២/០២ ក្នុងខែ ធ្នូ ឆ្នាំ ២០១៣។ សហព្រះរាជអាជ្ញាបានផ្តល់ការពន្យល់បន្តិចបន្តួច ចំពោះការស្នើសុំនេះ ដោយគ្រាន់តែបញ្ជាក់ថា ការដកចេញនេះដោយសារតែមន្ទីរសន្តិសុខគឺមិន "មានភាពពាក់ព័ន្ធស៊ីជម្រៅ" ជាមួយការចោទប្រកាន់អំពើប្រល័យពូជសាសន៍ជនជាតិចាម[32]។ ប៉ុន្តែនេះគឺជាការមិនត្រឹមត្រូវនោះទេ។ ភស្តុតាងនៅមន្ទីរសន្តិសុខក្រូចឆ្មារបង្ហាញថា ប្រសិនបើជនជាតិចាមត្រូវបានគេធ្វើបាបយ៉ាងវេទនា ក៏ការធ្វើបាបនេះគឺជាផលវិបាកផ្ទាល់ នៃការពិតដែលថាជនជាតិចាម បានដឹកនាំការបះបោរយ៉ាងធំធេង ប្រឆាំងបក្សកុម្មុយនីស្តកម្ពុជា។ ដីកាដំណោះស្រាយផ្ទាល់ក៏បានកត់សម្គាល់ពីមន្ទីរសន្តិសុខថា "ការចាប់ខ្លួន និងការឃុំខ្លួនជនជាតិចាម បានកើនឡើងក្រោយពេលមានការបះបោររបស់ជនជាតិចាម នៅក្នុងឆ្នាំ ១៩៧៥។ *ប្រជាជនដែលត្រូវបានចាប់ខ្លួន ត្រូវបានចាត់ទុកថាមានជាប់ពាក់ព័ន្ធនិងការបះបោរ*"[33]។

9. ដោយសារតែមានភាពកាន់តែច្បាស់លាស់ឡើង នៅពេលសវនាការលើការប្រព្រឹត្តចំពោះជនជាតិចាមកំពុងដំណើរការ ទើបសហព្រះរាជអាជ្ញាមានចេតនា ដកចេញនូវការបរិយាយនេះចេញពីការពិភាក្សាទាំងអស់តែម្តង។ សហព្រះរាជអាជ្ញាកំពុងតែផ្តោតទៅលើការចោទអំពីបទល្មើសប្រឆាំងនឹងជនជាតិចាម ដែលបានកើតឡើងបន្ទាប់ពីការមកដល់កម្មាភិបាលបកករបស់ភូមិភាគនិរតីនៅក្នុងឆ្នាំ ១៩៧៧ និង នៅឆ្នាំ១៩៧៨ នៅក្នុងភូមិភាគកណ្តាល (ឧត្តរចាស) និង ភូមិភាគបូព៌ា។ ដូច្នេះហើយមានបំណងបញ្ចៀសនូវឧក្រិដ្ឋកម្មដែលបង្កឡើងដោយមន្ត្រីរដ្ឋាភិបាលបច្ចុប្បន្ន។ ការ

---

[31] ឯកសារ **E301/9/1.1**, 'ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធសំណុំរឿង ០០២/០២', ERN 00981687 (នៅត្រង់ 2(iv)(a))។

[32] ឯកសារឯកសារ **E301/2**, 'សារណារបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធវិសាលភាពនៃសំណុំរឿង ០០២/០២ និងកាលបរិច្ឆេទសវនាការ ជាមួយឧបសម្ព័ន្ធ ក', ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣, កថាខណ្ឌ ១១។

[33] ឯកសារ **D427**, ដីកាដំណោះស្រាយ, កថាខណ្ឌ ៧៧៣ (ដោយគូសបញ្ជាក់បន្ថែម ហើយជើងទំព័រត្រូវបានលុបចេញ)។

ដកមន្ទីរសន្តិសុខក្រូចឆ្មារចេញពីវិសាលភាពនៃសវនាការ គឺជាជំហានមួយយ៉ាងសំខាន់ក្នុងការសម្រេចឱ្យបាននូវលទ្ធផលនេះ។

10. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ព័ត៌មានថា ខ្លួននឹងកំណត់កាលបរិច្ឆេទសម្រាប់សាក្សីត្រឹមតែ ១១នាក់ ដើមបណ្តឹងរដ្ឋប្បវេណី ៣នាក់ និងអ្នកជំនាញម្នាក់ប៉ុណ្ណោះ សម្រាប់ការផ្តល់សក្ខីកម្មអំពីការប្រព្រឹត្តិចំពោះជនជាតិចាម (រួមបញ្ចូលទាំងបទចោទជាច្រើន នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទចោទមួយ នៃបទចោទស្តីពីអំពើប្រល័យពូជសាសន៍ទាំងពីរ ក្នុងសំណុំរឿង ០០២/០២) ក្នុងអំឡុងពេលនៃសវនាការសរុបតែត្រឹម១៧ថ្ងៃ[34]។ សវនាការលើការប្រព្រឹត្តិចំពោះជនជាតិចាមចាប់ផ្តើមនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៥។ ចាប់ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៥ សាក្សីមួយរូប (អ៊ីត សេន) និងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប (សុះ ពន់យ៉ាមីន) ដែលពួកគាត់ទាំងពីរគឺជាអ្នកភូមិចាម បានផ្តល់ព័ត៌មានលម្អិតស្តីពីការប្រព្រឹត្តិចំពោះជនជាតិចាម នៅក្នុងតំបន់ ២១ នៃភូមិភាគបូព៌ា ដោយរួមបញ្ចូលទាំងបញ្ហានៃការបះបោររបស់ចាម នៅកោះផល និងស្វាយឃ្លាំង ហើយប្រហែលជានៅភូមិទ្រាផងដែរ។ ក្នុងអំឡុងពេលសវនាការផ្នែកនេះ សាក្សីប្រាំនាក់ទៀតនឹងត្រូវមកផ្តល់សក្ខីកម្ម អំពីព្រឹត្តិការណ៍នៅក្នុងតំបន់ ២១ ក្នុងឆ្នាំ១៩៧៧ និង ១៩៧៨៖ អ្នកភូមិចាមពីរនាក់, កម្មាភិបាលកម្រិតឃុំម្នាក់, កម្មាភិបាលកម្រិតស្រុកម្នាក់ និងលេខាស្រុកម្នាក់[35]។

## គ. សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំសាក្សីបន្ថែម និងសំណើសុំផ្អាកសវនាការនាពេលបន្ទាប់

11. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិ Nicholas Koumjian ដោយមិនមានការគាំទ្រពីដៃគូរជាតិរបស់ខ្លួន បានដាក់សំណើសុំកោះហៅសាក្សីបន្ថែមបីនាក់ទៀត សម្រាប់ផ្នែកជនជាតិចាម ដែលក្នុងនោះសាក្សីពីរនាក់ត្រូវបានស្នើសុំរួចមកហើយ នៅក្នុងបញ្ជីសាក្សីសំណុំ

---

[34] 'សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើជូនភាគីនានា', ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៥។

[35] ទោះបីជាយ៉ាងណាក៏ដោយសាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងនេះអាចអ្នកខ្លះមិនអាចមកបានដោយសារបញ្ហាសុខភាព៖ សារអេឡិចត្រូនិចពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ២៥ កញ្ញា ឆ្នាំ ២០១៥។

រឿង ០០២/០២ របស់សហព្រះរាជអាជ្ញា[36] ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមិនបានជ្រើសរើស នៅក្នុងបញ្ជីសាក្សីរបស់ខ្លួនសម្រាប់ការប្រព្រឹត្តិចំពោះជនជាតិចាមឡើយ។ មេធាវីការពារក្តីបានដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរ ចំពោះសំណើនេះនៅថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១៥។ នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ បន្ទាប់ពីមានសារណាផ្ទាល់មាត់របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសនៅក្នុងសាលសវនាការ និងតាមរយៈសារអេឡិចត្រូនិកថា នឹងមិនមានសវនាការឡើយនៅក្នុងសប្តាហ៍ ចាប់ពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៥[37] ហើយសវនាការនឹងបន្តធ្វើឡើងចាប់ពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥[38] ហើយអង្គជំនុំជម្រះនឹងបន្តសវនាការស្តាប់សក្ខីសកម្មដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន លើការប្រព្រឹត្តិចំពោះជនជាតិចាម។

12. មេធាវីការពារក្តីបានបញ្ជាក់នៅអំឡុងពេលសវនាការនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៥ថា ខ្លួននឹងដាក់សំណើនេះ[39] ព្រមទាំងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំសាក្សីបន្ថែម ("ចម្លើយតប")[40]។ នៅថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានផ្ញើសំណៅឯកសារជាមុនរបស់សំណើនេះជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង "ដោយសារតែសំណើនេះអាចធ្វើឲ្យប៉ះពាល់ដល់កាលវិភាគសវនការរបស់អង្គជំនុំជម្រះសាលាដំបូង" ហើយនៅបន្ទាប់មកនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១៥ ខ្លួនបានដាក់ចម្លើយតប។

## ឃ. របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) "*៣០ឆ្នាំរបស់ហ៊ុន សែន*"

[36] ឯកសារ E366, 'សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំកោះហៅសាក្សីបន្ថែម ក្នុងអំឡុងផ្នែកសវនាការសំណុំរឿង ០០២/០២ ស្តីពីការប្រព្រឹត្តិចំពោះជនជាតិចាម', ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ("សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំកោះហៅសាក្សីបន្ថែម")។

[37] ពង្រាងប្រតិចារឹកថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥, ទំព័រ ៤៧, ជួរ ១៥, ទំព័រ ៤៨, ជួរ ២។ ទំព័រ ៤៨, ជួរ ១០ ដល់១៤។ 'សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះសាលាដំបូងផ្ញើរជូនភាគី', ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥។

[38] ពង្រាងប្រតិចារឹកថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥, ទំព័រ ៨០, ជួរ ១៦ ដល់១៨។ 'សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះសាលាដំបូងផ្ញើរជូនភាគី', ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥។

[39] សូមមើលផងដែរ E1/349.1 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ប្រតិចារិត ទំព័រ ៥ បន្ទាត់ ២២ ដល់២៤។

[40] សូមមើលផងដែរ E1/349.1 ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ប្រតិចារិត ទំព័រ ១០ បន្ទាត់ ២ ដល់១០។

13. នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ផ្នែកសិទ្ធិមនុស្ស បានចេញរបាយការណ៍ដ៏សំខាន់មួយ ដែលមានចំណងជើងថា *៣០ឆ្នាំរបស់ហ៊ុន សែន អំពើហិង្សា ការបង្រ្កាប និងអំពើពុករលួយក្នុងប្រទេសកម្ពុជា* (“របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស”)។ របាយការណ៍នេះមិនត្រឹមតែផ្តល់នូវទិដ្ឋភាពទូទៅ នៃរយៈពេល៣០ឆ្នាំរបស់ ហ៊ុន សែន ក្នុងនាមជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវព័ត៌មានដ៏កម្រ អំពីតួនាទីរបស់គាត់ក្នុងនាមជាកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា នៅភូមិភាគបូព៌ា ដោយរួមបញ្ចូលទាំងការចូលរួមរបស់គាត់ក្នុងការប្រព្រឹត្តិលើជនជាតិចាមនៅក្នុងតំបន់ ២១។ នេះគឺជាការសម្ងាត់ដែលមិនត្រូវបានរក្សាទុកដោយល្អ ហើយរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស ត្រូវបានតាក់តែងឡើងដោយ Stephen Heder បើទោះបីជាគាត់មិនត្រូវបានគេទទួលស្គាល់ជាផ្លូវការថា ជាអ្នកតាក់តែងអត្ថបទនេះក៏ដោយ។ ដូចដែលមេធាវីការពារក្តីអះអាងនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ថាៈ

> ប្រហែលជាមិនមានអ្នកនៅរស់ណាម្នាក់ដែលពាក់ព័ន្ធដោយផ្ទាល់ខ្លាំងជាង ឬមានការទទួលខុសត្រូវខ្ពស់ជាងក្នុងការកសាងសំណុំរឿងប្រឆាំងនឹង នួន ជា នៅក្នុងតុលាការនេះឡើយ។ លោក Heder បានព្រាងប្លង់សម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅខែ មីនា ឆ្នាំ ២០០៤ ព្រមទាំងចេញផ្សាយសៀវភៅ *Seven Candidates for Prosecution* [41] ដោយបញ្ចូលការយោងយ៉ាងច្បាស់ទៅលើធាតុផ្សំនៃឧក្រិដ្ឋកម្ម ដែលគាត់ជឿជាក់ថា នួន ជា ទទួលខុសត្រូវ។ បន្ទាប់មកគាត់បំពេញការងារជាមួយសហព្រះរាជអាជ្ញានៅពេលដែលដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានព្រាង ហើយបន្ទាប់មក គាត់បានបំពេញការងារជាមួយសហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការស៊ើបអង្កេតលើដីកាសន្និដ្ឋានទាំងអស់នោះ ព្រមទាំងព្រាងដីកាដំណោះស្រាយទៀត[42]។

14. នៅពេលដែលរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សមិនបានផ្តល់កិត្តិយសដល់ Heder ជាអ្នកតាក់តែង វាមិនបានបញ្ជាក់ថា របាយការណ៍នេះផ្អែកលើប្រភពព័ត៌មានយ៉ាងច្រើនដូចខាងក្រោមៈ

> ព័ត៌មានជាភាសាខ្មែរ ភាសាអង់គ្លេស ភាសាវៀតណាម និងភាសាចិន។ ព័ត៌មានទាំងនេះរួមមានឯកសារផ្លូវការកម្ពុជា និងឯកសារកម្ពុជាដទៃទៀត, ការសម្ភាសន៍ជាមួយមន្ត្រីកម្ពុជា និងប្រជាជនកម្ពុជាដទៃទៀត ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស អង្គការក្រៅរដ្ឋាភិបាលដទៃទៀត អ្នកសារព័ត៌មាន និងអ្នកសិក្សាស្រាវ

---

[41] ឯកសារ **E3/48**, Stephen Heder, ‘Seven Candidates for Prosecution’ ខែ មីនា ឆ្នាំ ២០០៤។

[42] ឯកសារ **F16**, បណ្តឹងសាទុក្ខ កថាខណ្ឌ ១៨២។

ជ្រាវ កំណត់ត្រារបស់អង្គការសហប្រជាជាតិ របាយការណ៍រដ្ឋាភិបាលបរទេស និងកិច្ចដំណើរការនីតិវិធីតុលាការកម្ពុជា។

15. ក្រុមមេធាវីការពារក្តី ខៀវ សំផន បានព្យាយាមរួចហើយក្នុងការដាក់បញ្ចូល សម្រង់មួយចេញពីរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស (ជំពូក២) ធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ដែលបង្ហាញពីការចូលរួមរបស់ ហ៊ុន សែន នៅក្នុងការប្រព្រឹត្តិចំពោះជនជាតិចាម នៅក្នុងតំបន់ ២១[43]។ បើទោះបីជាសម្រង់នោះមានភាពពាក់ព័ន្ធយ៉ាងប្រត្រក្យ និងច្បាស់លាស់យ៉ាងណាក៏ដោយ តែអង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ ដោយផ្អែកលើមូលដ្ឋាននៃវិធីសាស្ត្រស្រាវជ្រាវ ដែលមានកំហុសឆ្គងយ៉ាងជាក់ស្តែងរបស់របាយការណ៍នេះ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ហាក់ដូចជារបាយការណ៍វាយតម្លៃលើប្រភពជាច្រើនខុសៗគ្នា ដែលបានយោងនៅក្នុងនោះ ហើយមិនមែនជារបាយការណ៍វាយតម្លៃលើប្រភពដែលបានលើកឡើងនោះឡើយ" និយាយម្យ៉ាងទៀតគឺថារបាយការណ៍នេះគ្រាន់តែជាការប្រមូលផ្តុំយ៉ាងច្រើន នូវព័ត៌មានបន្ទាប់បន្សំ ដែលត្រូវបានទទួលយកធ្វើជាភស្តុតាង ហើយដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកយ៉ាងច្រើន នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ របស់ខ្លួន។ ប៉ុន្តែ នៅក្នុងករណីពិសេសមួយនេះ អង្គជំនុំជម្រះបែរជាចាត់ទុកថា របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "មិនសមស្របសម្រាប់បញ្ជាក់ពីអង្គហេតុ ដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងឡើយ ហើយ[]ក៏មិនមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះដែរ"[44]។ ផ្អែកលើសេចក្តីសម្រេចនេះអង្គជំនុំជម្រះសាលាដំបូងបានហាមឃាត់មិនឲ្យមេធាវីការពារក្តីយោងទៅរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សនៅក្នុងអំឡុងពេលសួរដេញដោលសាក្សីទីមួយអំពីការប្រព្រឹត្តលើជនជាតិចាមក្នុងតំបន់២១[45]។ មេធាវីការពារក្តីកត់សម្គាល់ថា នៅពេលនោះថា ការនេះបាននាំទៅដល់ "ការព្យាយាមលាក់ការពិតអំពីអ្វីដែលបានកើតឡើង"[46]។ អាស្រ័យហេតុនេះ

---

[43] ឯកសារ E347, 'សំណើសុំដាក់បញ្ចូលឯកសារថ្មីៗទៅក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៥។

[44] ឯកសារ E347/1, 'សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកធ្វើជាភស្តុតាងថ្មី ក្នុងសំណុំរឿង ០០២/០២', ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥, កថាខណ្ឌ ៤។

[45] ប្រតិចារិត សវនាការ ថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ២៥ បន្ទាត់២៤ ទំព័រ ២៦ បន្ទាត់៤។

[46]ឯកសារ E1/343.1 ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ២០១៥ ទំព័រ ២៦ បន្ទាត់ ៨ ដល់៩។

ហើយ មេធាវីការពារក្តីនឹងធ្វើការស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងក្នុងពេលឆាប់ៗនេះឲ្យធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចនេះ នៅក្នុងសំណើនាពេលខាងមុខ ហើយនឹងធ្វើការសម្រេចទៅលើសំណើនោះ មុនពេលសាក្សីអ្នកជំនាញ Ysa Osman មកបង្ហាញខ្លួន។

## III. ច្បាប់ជាធរមាន

16. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ភាគីនៅគ្រប់ដំណាក់កាលនីតិវិធីក្នុងអំឡុងពេលជំនុំជម្រះអាចស្នើសុំអង្គជំនុំជម្រះឲ្យ "កោះហៅ ឬ ស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬ ទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" ក្នុងករណី "សក្ខីកម្ម ឬ ភស្តុតាង ដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ" និងផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧ (៣)។ ក្នុងករណីសក្ខីកម្ម ឬ ភស្តុតាង ដែលបានស្នើសុំនោះអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ អង្គជំនុំជម្រះបានសម្រេចរួចហើយថា អង្គជំនុំជម្រះអាចទទួលយកបាន "ដរាបណាផលប្រយោជន៍នៃយុត្តិធម៌តម្រូវ ជាពិសេស ដរាបណាភស្តុតាងទាំងនេះជាភស្តុតាងដោះបន្ទុកដែលតម្រូវឲ្យធ្វើការវាយតម្លៃដើម្បីជៀសវាងការសម្រេចសេចក្តីដោយអយុត្តិធម៌"[47] ឬ ក្នុងករណីដែល "ភស្តុតាងទាក់ទងជិតស្និទ្ធទៅនឹងឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង [...] ផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យវាយតម្លៃប្រភពទាំងនេះរួមគ្នា"[48]។ ដើម្បីបំពេញលក្ខខណ្ឌតម្រូវក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ភស្តុតាងទាំងឡាយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងចាំបាច់គ្រាន់តែជាភស្តុតាងពាក់ព័ន្ធ និងអាចទុកចិត្តបាន*ជាបឋម*ជាការស្រេច[49]។

17. វិធាន ៩១ នៃវិធានផ្ទៃក្នុងផ្តល់អំណាចឲ្យអង្គជំនុំជម្រះសាលាដំបូង "ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋ

---

[47] ឯកសារ E307/1 "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)" ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ កថាខណ្ឌ៣ *ស្របគ្នាជាមួយនឹង*ឯកសារ E190 "សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត" ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ៣៦។

[48] ឯកសារ E289/2 "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E289/1)" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ កថាខណ្ឌ៣។

[49] ឯកសារ E313 "សាលក្រមសំណុំរឿង ០០២/០១" ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ២៦។

ឬវេណី សាក្សី និងអ្នកជំនាញទៅតាមលំដាប់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍”។ យោង តាមវិធាននេះ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចនៅក្នុងសំណុំរឿង ០០២/០២ រួចហើយ ថា ការស្តាប់សក្ខីកម្មសាក្សី [redacted] គួរតែពន្លឿន ធ្វើឡើងដោយហេតុថា “បើទោះជា [redacted] ពាក់ព័ន្ធខ្លាំងបំផុតទៅនឹងអង្គហេតុដែលត្រូវបានគ្រោងសម្រាប់ពេលក្រោយៗនៅក្នុងសំណុំរឿង ០០២/០២ ក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថាជាការសមស្រប ដែលត្រូវស្តាប់សក្ខីកម្មរបស់ [redacted] ក្នុងអំឡុងពេលពិនិត្យលើអង្គហេតុដំបូងៗ ប្រសិនបើគាត់អាចចូលរួមបាននោះ”[50]។

## IV. ឧឡឹករណ៍

### ក. សាក្សីចំនួនពីររូបដែលត្រូវពន្លឿនការកោះហៅ៖ [redacted] និង [redacted]

18. ដូចមេធាវីការពារក្តីធ្លាប់បានបញ្ជាក់នាពេលមុនរួចមកហើយថា មិនគ្រាន់តែ [redacted] ដែលជាសាក្សីសំខាន់នៅក្នុងសំណុំរឿង ០០២/០១ ទាក់ទងនឹងការជម្លៀសពីទីក្រុងភ្នំពេញ និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅទួលពោធិជ្រៃនោះទេ[51] តែថែមទាំង “ប្រាកដណាស់នៅតែជា*សាក្សីដ៏សំខាន់នៅក្នុងសំណុំរឿង ០០២/០២ និងសំណុំរឿង ០០២ ជាទូទៅ*”[52]ផងដែរ។ [redacted] នៃបណ្តឹងដិតចិត្តលើកទីពីរ មេធាវីការពារក្តីបានពីពណ៌នាអំពីការរំពឹងលើសក្ខីកម្មរបស់ [redacted] នៅក្នុងសំណុំរឿង ០០២/០២ ដូចខាងក្រោម៖

> ក្នុងនាមជាឥស្សរជនជាន់ខ្ពស់ម្នាក់នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ដែលគាំទ្រដោយវៀតណាមដែលបានធ្វើការប្រឆាំង និងចុងក្រោយបានផ្តួលរំលំក្រុមដែលដឹកនាំដោយ ប៉ុល ពត និង នួន ជា នៅក្នុងសំណុំរឿង ០០២/០២ [redacted] នឹងអាចផ្តល់ជូននូវភស្តុតាងផ្ទាល់ពិសេសអំពី *ក្នុងចំណោមប្រការផ្សេងទៀត* ផ្នែកផ្ទៃក្នុងរបស់បក្សកុម្មុយនិស្តកម្ពុជាដែលរត់ចេញពីប្រទេស និងការចោទប្រកាន់អំពីប្រល័យពូជសាសន៍ជន

---

[50] [redacted]។

[51] F16 បណ្តឹងសាទុក្ខ [redacted]

[52] [redacted]។

ជាតិវៀតណាម និងជនជាតិចាមនៅក្នុងភូមិភាគបូព៌ា[53]។

19. ចំណែក [redacted] ប្រហែលជាសាក្សីសំខាន់បំផុតទីពីរនៅក្នុងសំណុំរឿង ០០២/០២ នឹងអាចផ្តល់សក្ខីកម្មលើបញ្ហាគន្លឹះជាច្រើនដែលកំពុងធ្វើការតវ៉ានៅក្នុងសំណុំរឿង ០០២/០២។ ទាក់ទងនឹងការការយោងជាក់លាក់អំពីប្រធានបទក្នុងសវនាការបច្ចុប្បន្នអំពីការប្រព្រឹត្តលើជនជាតិចាម មេធាវីការពារក្តីកត់សម្គាល់ឃើញថា កងកម្លាំងយោធាភូមិភាគបូព៌ាបានជាប់ពាក់ព័ន្ធយ៉ាងជ្រៅនៅក្នុងការបង្ក្រាបការបះបោរជនជាតិចាមដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ រួមទាំងការបះបោរនៅភូមិកោះផល ភូមិស្វាយឃ្លាំង និងភូមិទ្រា ដែលអាស្រ័យហេតុនេះហើយ ទាំង [redacted] និង [redacted] អាចផ្តល់សក្ខីកម្មអំពីសកម្មភាពទាំងនេះ។

20. [redacted] ស្ថិតនៅក្រោមលេខាភូមិភាគបូព៌ា សោ ភឹម ក្នុងឋានានុក្រមយោធាភូមិភាគត្រឹមតែពីរថ្នាក់ប៉ុណ្ណោះនៅក្នុងឆ្នាំ១៩៧៥។ តាមការទទួលស្គាល់របស់គាត់ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៥ [redacted]កងកម្លាំងយោធាទាំងអស់នៅភូមិភាគបូព៌ា សមាជិកគណៈភូមិភាគបូព៌ា និង[redacted] នៅភូមិភាគបូព៌ា[54]។ គាត់ក៏ជាប់ទំនាក់ទំនងគ្រួសារជាមួយនឹងតំបន់ ២១ ក្នុងភូមិភាគបូព៌ាផងដែរដោយសារថាប្អូនស្រីរបស់គាត់ឈ្មោះ [redacted] បានរៀបការជាមួយនឹង[redacted]តំបន់ ២១ [redacted][55]។ ចំណែក [redacted] ក៏ស្ថិតនៅក្រោម សោ ភឹម ក្នុងឋានានុក្រមស៊ីវិលភូមិភាគបូព៌ាតែមួយថ្នាក់ផងដែរ។ ចាប់ពីខែកក្កដា ឆ្នាំ១៩៧៥

---

53 [redacted]។

54 [redacted] *សូមមើលផងដែរ* ឯកសារ E3/1593 Ben Kiernan *របបប៉ុលពត* ERNs 00678511 និង 00678542 (ទំព័រ ៣២ និង៩៥)។

55 [redacted] (ដែលបានលើកឡើងថា "ខ្ញុំបាត់បងប្អូនថ្លៃបីនាក់។ [ទីមួយឈ្មោះ] [redacted] ត្រូវជាប្តីរបស់ [redacted] [redacted])។ *សូមមើលផងដែរ* ឯកសារ E3/494 "របាយការណ៍អ្នកជំនាញការ Craig Etcheson" ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ERN 00142836។

រហូតដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨[56] គាត់បានបម្រើការងារជា [redacted] តំបន់ ២១ នៅភូមិភាគបូព៌ា [redacted][57]។ និយាយឲ្យខ្លីមក [redacted] គឺជាសមាជិកជាន់ខ្ពស់បំផុតនៃរចនាសម្ព័ន្ធអំណាចនៅភូមិភាគភូមិបូព៌ាដែលនៅរស់រានមានជីវិតមកទល់សព្វថ្ងៃ ហេតុនេះហើយគាត់មិនគ្រាន់តែដឹងលើអំពីរចនាសម្ព័ន្ធនៅក្នុងភូមិភាគបូព៌ាជាទូទៅ និងតំបន់២១ជាពិសេសនោះទេ[58] តែលើសពីនេះនោះ គាត់ទំនងជាដឹងឮដោយផ្ទាល់អំពីបញ្ហាដែលបានចេញមកពីថ្នាក់កំពូលបំផុតនៃឃោធាភូមិភាគទៅថ្នាក់ស្រុក និងឃុំ និងវិសាលភាពដែលបញ្ហាទាំងនោះ ប្រសិនបើពុំខុសទេ ពីដំបូងបានចេញមកពីគណៈអចិន្ត្រៃយ៍ ឬ គណៈមជ្ឈិម ឬ បើពុំដូច្នោះទេបានផ្តួចផ្តើមនៅក្នុងភូមិភាគនេះ។ ព័ត៌មានបែបនេះមានសារសំខាន់ និងពុំមានអ្វីជំនួសបានសម្រាប់បង្ហាញថាតើវាមានគោលនយោបាយកំណត់គោលដៅជនជាតិចាមនៅក្នុងតំបន់ ២១ នៅភូមិភាគបូព៌ា និងប្រសិនបើមែននោះ ថាតើគោលនយោបាយនេះនៅទីបំផុតមានអ្វីទាក់ទងនឹង នួន ជា ដែរឬទេ។

21. តាមពិតទៅ ភ័ស្តុតាងនៅក្នុងសំណុំរឿងលើកឡើងថា សាក្សីទាំងពីរដឹងឮជាក់លាក់ និងលម្អិតអំពីការប្រព្រឹត្តលើជនជាតិចាមនៅភូមិភាគបូព៌ា។ នៅក្នុងកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹង Ben Kiernan ក្នុងឆ្នាំ១៩៨១ [redacted] ចោទប្រកាន់ថា ប៉ុល ពត គ្រាន់តែ "ឲ្យពួកចាមអនុវត្តគោលនយោបាយដូចប្រជាជនខ្មែរធម្មតាដែរ" ហើយកត់សម្គាល់ថា ការបះបោរបានកើតឡើងមែន[59]។ លើសពីនេះ ដោយសារនៅពេលនេះ ជា ស៊ីម បានទទួលមរណភាពហើយនោះ [redacted] (តាមអ្វីដែលយើងដឹង) គឺជាសាក្សីតែម្នាក់គត់ដែលនៅរស់ក្នុងចំណោមសាក្សីមួយចំនួនតូចដែលសហព្រះរាជអាជ្ញាបានសំអាងក្នុងការបង្ហាញជាមូលដ្ឋានលើការអះអាងរបស់ខ្លួននៅក្នុងសេចក្តីសន្និដ្ឋានស្ថាពរថា "ប៉ុល ពត ជាលេខា ប.ក.ក បានធ្វើសេចក្តីថ្លែងការណ៍ដោយអំពាវនាវឲ្យធ្វើទុក្ខបុក

---

56 [redacted]។

57 [redacted]។

58 *សូមមើលផងដែរ* [redacted]

59 [redacted]។

ម្នេញ និងបំផ្លិចបំផ្លាញទៅលើជនជាតិចាម"[60] ហើយនៅសន្និបាតរបស់មេដឹកនាំ ប.ក.ក នាថ្ងៃទី ២០ ខែឧសភា ឆ្នាំ១៩៧៥ ក្នុងក្រុងភ្នំពេញ កម្មាភិបាលត្រូវបានណែនាំអំពីផែនការស្ដីពីគោលនយោបាយប្រាំបីចំនុចរបស់ ប.ក.ក ដែលចំណុចទីប្រាំគឺ "ត្រូវលុបបំបាត់វាល់សាសនាដោយសារវាសុទ្ធតែប្រតិកិរិយា"[61]។ គាត់ក៏ជាសាក្សីតែម្នាក់គត់ដែលសហព្រះរាជអាជ្ញាបានសំអាងនៅក្នុងសេចក្ដីសន្និដ្ឋានស្ដាពរនៅពេលដែលបានអះអាងថា នៅសន្និបាតនាថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ "ប៉ុល ពត បានណែនាំឲ្យកម្មាភិបាល ប.ក.ក ត្រូវបង្ខំជនជាតិចាមឲ្យចិញ្ចឹមជ្រូក និងទទួលទានសាច់ជ្រូក ហើយប្រសិនបើជនណាមួយជំទាស់នឹងត្រូវសម្លាប់ចោល"[62]។ នៅក្នុងកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹង Kiernan [redacted] ក៏បានបង្ហាញការយល់ឃើញរបស់ខ្លួនប្រហែលជាទាក់ទងនឹងការបះបោរនៅកោះផលថា៖

> [ទាក់ទងនឹង]ការបង្ក្រាបប្រជាជនចាម កងទ័ពរបស់[ខ្ញុំ]មិនបានទៅចូលរួមទេ[]។ <u>វាជាសន្តិសុខ[]របស់មូលដ្ឋាន ឃុំ ភូមិ ស្រុក។</u> វាទើបតែត្រូវបានបង្កើតថ្មីនៅជិត[ពាក្យខ្មែរមិនច្បាស់]កោះ នោះ[63]។

22. សហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានស្ដាពររបស់ខ្លួនថា បកក អនុវត្តគោលនយោបាយប្រល័យពូជសាសន៍ "ដើម្បីកម្ទេចក្រុមជាតិពន្ធុ និងក្រុមចាម"[64]។ តែ [redacted] បានលើកឡើងផ្ទុយទៅវិញថា ការប្រព្រឹត្តលើជនជាតិចាមគឺដោយសារតែនិន្នាការបំបែកខ្លួន។ គាត់បានពិពណ៌នានៅក្នុងកិច្ចសម្ភាសន៍មួយផ្ដល់ជូន Stephen Heder អំពីករណីថាតើយ៉ាងហោចណាស់ការបះបោរពីររបស់ជនជាតិចាមកើតឡើងដោយរបៀបណា។ គាត់បានបង្ហាញអត្ត

---

[60] ឯកសារ D390 ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៥៥ លេងយោងជើងទំព័រ ៣៧៦៧ (ដែលសាក្សីម្នាក់ទៀតក្រៅពី [redacted] ដែលត្រូវបានយកមកសំអាងគឺសព ជា ស៊ឹម)។ សូមមើលកថាខណ្ឌ ៥ខាងលើ។

[61] ឯកសារ D390 ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៥៧ លេងយោងជើងទំព័រ ៣៧៧៤ (ដែលប្រភពតែមួយគត់គឺចេញមកពីសព មាត់ លី ដូចបានដកស្រង់នៅក្នុងសៀវភៅ អ៊ីសា ឧស្មាន និងសព ជា ស៊ឹម)សូមមើលកថាខណ្ឌ ៥ ខាងលើ។។

[62] ឯកសារ D390 ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៥៧ លេងយោងជើងទំព័រ ៣៧៧៥។

[63] ឯកសារ E3/1568 កិច្ចសម្ភាសន៍របស់ Kiernan ជាមួយនឹង ជា ស៊ឹម-[redacted] ERN 00651891 (ចំណារក្នុងឯកសារដើម ការគូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ឯកសារ E3/1593 Ben Kiernan *របបប៉ុលពត* ERNs 00678636 (ទំព័រ ២៦៥) ពិពណ៌នាសក្ដីកម្មរបស់ [redacted] ពាក់ព័ន្ធនឹងចំណុចនេះ ហើយបានកត់សម្គាល់ថា Stephen Heder បានទាញសេចក្ដីសន្និដ្ឋានដូចគ្នា។

[64] ឯកសារ D390 ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៥៣។

សញ្ញាណដំបូងអំពីហ៊ុលរ៉ូចំប៉ាដែលគាត់បាននិយាយថា បានដឹកណាំដោយ Sabuon Leskanen និង "មានចេតនាបង្កើត*រដ្ឋនៅក្នុងរដ្ឋ*ពីព្រោះថាជនជាតិចាមមានបំណងចង់កាន់កាប់ទឹកដីកម្ពុជាភាគខាងកើតទន្លេមេគង្គរហូតដល់អាណាមកណ្ដាល [ពោលគឺ វៀតណាម] ដើម្បីបង្កើតរដ្ឋ"[65]។ ទីពីរគឺក្បាល ឬ ទំនងជាខ្មែរស (ត្រូវបានបកប្រែថាខ្មែរស) ដែលគាត់បានពិពណ៌នាថាជា "ប្រតិបត្តិការណ៍នៅទូទាំងប្រទេសក្នុងឆ្នាំ១៩៧៣-ឆ្នាំ១៩៧៤ ដោយមានសមាសភាពជនជាតិខ្មែរ និងជនជាតិចាម។ [...] សម្រាប់អ្នកដែលត្រូវបានចាប់ខ្លួន ពួកគេបានឆ្លើយទម្លាក់កំហុសថា វៀតណាមគឺជាអ្នកដែលបានបញ្ជាពួកគេឲ្យទម្លាក់របបប៉ុលពតនៅពេលនោះ"[66]។ [redacted] ក៏បានលើកឡើងអំពីអត្ថិភាពនៃចលនាបះបោរមួយទៀតមានឈ្មោះស្រដៀងគ្នាដែលគាត់បានហៅថាជា "ក្បាលស" ចំណែកអត្ថបទក្នុងឆ្នាំ១៩៧៤ មួយក្នុង*កាសែតវ៉ាស៊ីងតោនប៉ុស្តិ៍* និពន្ធដោយអ្នកកាសែត James Fenton បានរៀបរាប់បន្តរបាយការណ៍ជនភៀសខ្លួនអំពី៖

> កងកម្លាំងបះបោរនៅក្នុងខេត្តកំពង់ចាម ដែលក្រុមមួយហៅថាខ្មែរសបានបំបែកខ្លួនចេញពីពួកខ្មែរក្រហម ហើយត្រឡប់ទៅចូលក្នុងព្រៃ។ ពួកខ្មែរសដែលមេដឹកនាំរបស់ពួកគេជាអតីតមន្ត្រីកុម្មុយនីស្តគឺភាគច្រើនជា<u>ពួកមូស្លីមចាម</u>។ ពួកនេះគាំទ្រសីហនុ និងប្រឆាំងនឹងសមូហភាពហូបនីយកម្មទ្រព្យសម្បត្តិ។ ពួកគេជាធម្មតាជឿលើការលុបបំបាត់ជនកណ្ដាល[67]។

23. ភ័ស្តុតាងទាំងនេះអាចផ្ដល់ជូននូវការពន្យល់មួយផ្សេងអំពីការជម្រុញឲ្យកើតមានការបះបោរជនជាតិចាមនានាពីដំបូងនៅក្នុងតំបន់ ២១ ក្នុងឆ្នាំ១៩៧៥។ [redacted] ក៏បានផ្ដល់ព័ត៌មានលម្អិតបន្ថែមអំពីការបះបោរទាំងនេះនៅក្នុងកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹង Heder។ គាត់ក៏បានពន្យល់អំពីករណីថា តើជនជាតិចាមបានបះបោរដោយរបៀបណានៅស្វាយឃ្លាំង "ប្រឆាំងជាមួយនឹងរដ្ឋអំណាចស្រុកហ្នឹងទៅចាប់ជនជាតិឥស្លាម" ចំណែកនៅកោះផល ជនជាតិចាម "បានកាប់កម្មាភិបាលឃុំមួយស្លាប់ ហើយដណ្ដើមបានអាវុធការ៉ូបីន"[68]។ គាត់ក៏បានពិពណ៌នាអំពី "ចលា

---

[65] [redacted]។

[66] [redacted]។

[67] សូមមើល ឯកសារ F2/8.1.30 James Fenton "កម្ពុជា៖ កុម្មុយនីស្តនិយមផ្លាស់ប្ដូររបៀបរបបរស់នៅ" *កាសែតវ៉ាស៊ីងតោនប៉ុស្តិ៍* ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៧៤ ទំព័រ K1 (ការគូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* ឯកសារ E3/1593 Ben Kiernan *របបប៉ុលពត* ERNs 00678529 (ទំព័រ ៦៨)។

[68] [redacted]។

ចលក្នុងស្រុកផ្សេងៗទៀតដែលមានជនជាតិឥស្លាម" ប៉ុន្តែនៅទីបំផុត ការបះបោររបស់ជនជាតិចាម "ត្រូវបាន*កំទេចចោល*ទាំងអស់"[69]។ ភស្តុតាងទាំងនេះគាំទ្រនូវការចោទប្រកាន់ថា ការបង្ក្រាបដោយតំបន់ ២១ នៅភូមិភាគបូព៌ាលើការបះបោររបស់ជនជាតិចាមក្នុងឆ្នាំ១៩៧៥ មានភាពសាហាវដូចការប្រព្រឹត្តលើជនជាតិចាមដូចបានចោទប្រកាន់ថាបានកើតឡើងនៅភូមិភាគមជ្ឈិម (ឧត្តរចាស់) ក្នុងឆ្នាំ១៩៧៧ និងនៅភូមិភាគបូព៌ាក្នុងឆ្នាំ ១៩៧៨ ដែលសហព្រះរាជអាជ្ញាបានសំអាង។ ភស្តុតាងទាំងនេះលើកឡើងថា នៅក្នុងការបង្ក្រាបការបះបោរក្នុងឆ្នាំ១៩៧៥ យោធាភូមិភាគបូព៌ាបានចាប់ប្រជាជន រួមទាំងអ្នកឈឺ "យកមកដាក់កាណូត និងបោះទម្លាក់ទៅក្នុងទឹកដែរ" "បំបែកក្បាលជនជាតិចាមដោយវាយនឹងដងចប" ហើយ "បានយកក្បាលមនុស្សមកដោតលើបង្គោលយ៉ាងច្រើនដើម្បីតាំងបង្ហាញឱ្យប្រជាជនឃើញនៅតាមបណ្ដោយច្រាំងទន្លេមេគង្គ"[70]។

24. ទោះបីជា [redacted] និង [redacted] មានភាពពាក់ព័ន្ធយ៉ាងខ្លាំងបំផុតនៅក្នុងសំណុំរឿង ០០២/០២ ប្រហែលជាជាមួយនឹងផ្នែកស្ដីពីជម្លោះប្រដាប់អាវុធជាមួយវៀតណាម "ការបោសសម្អាតផ្ទៃក្នុង"នៅក្នុងភូមិភាគបូព៌ា និងតួនាទីរបស់ នួន ជា ក៏ដោយ ក៏មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនអនុលោមតាមវិធាន ៩១ នៃវិធានផ្ទៃក្នុង ដើម្បីពន្លឿន និងកំណត់ការស្ដាប់សក្ខីកម្មរបស់ [redacted] និង [redacted] ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននៅក្នុងវគ្គទាក់ទងនឹងការប្រព្រឹត្តលើជនជាតិចាម។ ករណីនេះគឺពីព្រោះតែមេធាវីការពារក្ដីជឿជាក់ថា ការយល់ឃើញស៊ីជម្រៅពុំធ្លាប់បានឮនៅក្នុងហេតុការណ៍នានា រចនាសម្ព័ន្ធ សេចក្ដីសម្រេច និងគោលនយោបាយក្នុងតំបន់ ២១ នៅភូមិភាគបូព៌ាអាចនឹងជះឥទ្ធិពលយ៉ាងធំធេងលើការវិវឌ្ឍជាហូរហែរបស់អង្គជំនុំជម្រះ និងជំហរ និងការយល់ឃើញរបស់ភាគីអំពីហេតុការណ៍នានាទាក់ទងនឹងការប្រព្រឹត្តលើជនជាតិចាម។ សក្ខីកម្មរបស់ពួកគេក៏ទំនងជាជះឥទ្ធិពលលើសំណួរនានាដែលភាគី និងចៅក្រមសួរទៅកាន់សាក្សីដែលនៅសេសសល់នៅក្នុងអង្គហេតុស្ដីពីការប្រព្រឹត្តលើជនជាតិចាម ដែលជាហេតុបន្ថយអានុភាពចាំបាច់ត្រូវកោះហៅសាក្សីនានាសារជាថ្មីដើម្បីយកមកដេញដោលបន្ថែមទៀតនាកាលបរិច្ឆេទក្រោយៗ។

---

[69] [redacted]។

[70] ពាក់ព័ន្ធនឹងករណីនេះ សូមមើល ឯកសារ E3/1593 Ben Kiernan *របបប៉ុលពត* ERNs 00678636 (ទំព័រ ២៦៤-២៦៥) ដែលដកស្រង់ភស្តុតាងរបស់សាក្សីជនជាតិចាមឈ្មោះ Sop Khatidjah និង Kob Math ព្រមទាំង François Ponchaud។ ឯកសារ E243.1 François Ponchaud *កម្ពុជា៖ឆ្នាំសូន្យ* ERNs 00862093 (ទំព័រ ១៣៣)។

25. ជាងនេះទៅទៀតនោះ [redacted] និង [redacted] នឹងបង្ហាញការយល់ឃើញស៊ីជម្រៅលើផ្នែកស្នូលនៃរឿងក្ដីរបស់មេធាវីការពារក្ដី។ ផ្នែកស្នូលនេះគឺ ក្រៅពីមានឋានានុក្រម "វាងពីរ៉ាមីត" មានវិន័យ រួបរួមគ្នា ប.ក.ក ហ៊ុមព័ទ្ធទៅដោយការរង្គោះរង្គើផ្ទៃក្នុងរហូតមក ហើយក្រុមមានកម្លាំងខ្លាំងស្មើគ្នា និងផ្សេងៗគ្នា (រួមទាំងក្រុមមួយដែលបានដឹកនាំដោយលេខាភូមិភាគបូព៌ា សោ ភឹម និងលេខាភូមិភាគពាយ័ព្យ រស់ ញឹម) បានអនុវត្តកម្មវិធីប្រណាំងប្រជែងគ្នាក្នុងគោលបំណងចាប់យកការគ្រប់គ្រងទាំងមូលលើបក្ស និងប្រទេស ព្រមទាំងក្រុមមួយនោះក្នុងចំណោមក្រុមទាំងនេះក៏ព្យាយាមតស៊ូដើម្បីផលប្រយោជន៍យ៉ាងហោចណាស់សម្រាប់វៀតណាម បើមិនសម្រាប់សូវៀតទេនោះ។ ជំហរនេះត្រូវបានសង្ខេបនៅក្នុងសំណើសុំលើកទីប្រាំមួយដែលមេធាវីការពារក្ដីបានដាក់នាពេលថ្មីៗដើម្បីស្នើសុំឱ្យទទួលយកភ័ស្ដុតាងថ្មីដែលបានដាក់ជូនអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងអំឡុងបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១[71]។

## ខ. សាក្សីបន្ថែម៖ លោក ហ៊ុន សែន

26. ចាប់តាំងពីពាក់កណ្ដាលខែ មេសា ឆ្នាំ ១៩៧៥ លោក ហ៊ុន សែន គឺជាប្រធានសេនាធិការប្រចាំកងវរសេនាតូច ៥៥ នៅតំបន់ ២១ ភូមិភាគបូព៌[72]។ របាយការណ៍របស់ HRW ដកស្រង់ភ័ស្ដុតាងគួរឱ្យជឿជាក់ និងបញ្ជាក់បានដែលបង្ហាញថា យោធាដែលនៅក្រោមបញ្ជារបស់លោក ហ៊ុន សែន បានចូលរួមការបង្ក្រាបការបះបោររបស់ជនជាតិចាមនៅស្វាយឃ្លាំង[73]។ ជាពិសេស របាយការណ៍នេះ បង្ហាញថា៖

> ប្រហែលជានៅឆ្នាំ ១៩៧២ លោក ហ៊ុន សែន ត្រូវបានតែងតាំងជាមេបញ្ជាការអនុសេនាធំ ទទួលបន្ទុកកម្លាំងពិសេសចំនួនប្រហែល ១៣០ នាក់ ដែលជាផ្នែកមួយនៃកងមួយនៅតំបន់ ២១។ កងនេះគេដាក់ថា កងវរសេនាតូច ៥៥ ហើយសរុបមានកងអនុសេនាធំចំនួន ៣[...]។

---

[71] សូមមើល ឯកសារ F2/8 "សំណើលើកទីប្រាំមួយរបស់ នួន ជា សុំឱ្យពិចារណា និងទទួលយកភ័ស្ដុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ផ្នែកទី IV: ក្បាល និងកន្ទុយក្រពើ(កថាខណ្ឌ ២៤-៧០)។

[72] សូមមើល ឯកសារ **E347.3**, Human Rights Watch, *30 Years of Hun Sen: Violence, Repression, and Corruption in Cambodia*, ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ ("របាយការណ៍ HRW") ទំព័រ ១៩, ឯកសារ **E3/1593**, Ben Kiernan, *របបប៉ុល ពត*, ERN 00678687 (ទំព័រ ៣៧០), ឯកសារ **E3/5261**, 'កំណត់ហេតុស្ដាប់ចម្លើយសាក្សី សូ ស៊ីម៉ុច' ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៨ ERN 00274338។

[73] សូមមើល កថាខណ្ឌ ១៧ ខាងលើ។

បន្ទាប់ពីខែ មេសា ឆ្នាំ ១៩៧៥ ខណៈដែលសម្រាកនៅមន្ទីរពេទ្យ លោក ហ៊ុន សែន ត្រូវបានតែងតាំងជាប្រធានសេនាធិការកងវរសេនាធំពិសេសស្វយ័ត នៅភូមិភាគបូព៌ា ជាកងមួយក្នុងចំណោមកងវរសេនាធំចំនួនបី នៅតំបន់ផ្សេងៗនៅភូមិភាគនេះ។ តាមការអនុវត្តរបស់ ប.ក.ក នៅក្នុងរចនាសម្ព័ន្ធនេះ លេខាតំបន់របស់ ប.ក.ក អនុវត្តសិទ្ធិអំណាចលើយោធាតំបន់។ ដោយកើតចេញពីកងវរសេនាធំតំបន់ ២១ សម័យសង្គ្រាម កងវរសេនាធំនេះមានកងវរសេនាតូច ៥៥, ៥៩ និង ៧៥។ លោក ហ៊ុន សែន នៅពេលដំណាលគ្នានោះ គឺជាមេបញ្ជាការរងម្នាក់នៃកងវរសេនាធំនេះ ដូច្នេះ គាត់បានកាន់តំណែងនានាដែលឱ្យគាត់មានសិទ្ធិអំណាចលើកងកម្លាំងសរុបចំនួន ២, ០០០ នាក់នៅក្នុងកងវរសេនាធំនេះ។ នៅត្រឹមខែ ឧសភា ឆ្នាំ ១៩៧៥ លោក ហ៊ុន សែន មានលទ្ធភាពគ្រប់គ្រាន់ដើម្បីចូលរួមកិច្ចប្រជុំនានា ហើយក្រោយមកទៀតមិនយូរប៉ុន្មានគាត់បានចូលកងវរសេនាធំរបស់គាត់ ដែលត្រូវបានដាក់ពង្រាយទៅព្រំដែនជាមួយប្រទេសវៀតណាម នៅស្រុកមេមត់ តំបន់ ២១[74]។

27. របាយការណ៍របស់ HRW បន្តពិភាក្សាអំពីតួនាទីរបស់លោក ហ៊ុន សែន នៅក្នុងការបង្ក្រាបការបះបោរជនជាតិចាមនៅស្រុកក្រូចឆ្មារ តំបន់ ២១ នៅខែ កញ្ញា-ខែ តុលា ឆ្នាំ ១៩៧៥៖

ព័ត៌មានផ្សេងទៀត គឺខុសពីរឿងរ៉ាវរបស់លោក ហ៊ុន សែន ដោយព័ត៌មានទាំងនោះ បង្ហាញថា ទោះបីជាកងកម្លាំងស្រុកក្រូចឆ្មារ ប្រហែលជាអាចដោះស្រាយជាមួយភូមិកោះផល ដោយខ្លួនឯងក៏ដោយ ក៏ ក្រោយមក កងវរសេនាតូច ៥៥ នៃកងវរសេនាធំ តំបន់ ២១ បានចូលរួមដោយផ្ទាល់នៅក្នុងការវាយប្រហារស្វាយឃ្លាំង។ តាមសក្ខីកម្មរបស់អតីតយុទ្ធជនម្នាក់មកពីកងវរសេនាធំតំបន់ ២១ បានឱ្យដឹងថា បន្ទាប់ពីការបះបោរនេះបានកើតឡើង ហើយបានរាលដាលដល់ស្វាយឃ្លាំងរួចហើយនោះ កងវរសេនាតូច ៥៥ ត្រូវបានបញ្ជូនពីព្រំដែន ដើម្បីបង្ក្រាបការបះបោរនេះ។ សក្ខីកម្មនេះត្រូវបានបញ្ជាក់តាមព័ត៌មានរបស់អ្នកស្រុកក្រូចឆ្មារម្នាក់ដែលបានសង្កេតឃើញយោធាតំបន់ ២១ ចល័ត ទៅប្រយុទ្ធ ដោយគាត់និយាយថា កងនានាដែលបង្ក្រាបការបះបោររបស់ជនជាតិចាមនៅឆ្នាំ ១៩៧៥ គឺកងកម្លាំងយោធាស្រុកក្រូចឆ្មារ ដែលមានមូលដ្ឋាននៅស្រុកតាមទន្លេមេគង្គ និង កងវរសេនាតូច ៥៥ ដែលចូលមកក្រូចឆ្មារ ពីចម្ការកៅស៊ូទៅខាងត្បូង ដូច្នេះគឺមកពីឆ្ងាយ និងមកយឺតជាងកងកម្លាំងស្រុកក្រូចឆ្មារ។ ព័ត៌មាននេះស្របគ្នាជាមួយនឹងព័ត៌មានរបស់អ្នកភូមិម្នាក់នៅស្វាយឃ្លាំង ដែលនិយាយថា បន្ទាប់ពីយោធាស្រុកក្រូចឆ្មារ ឃើញលេចចេញពីខាងលិចមក ក៏មានយោធារាប់រយនាក់ផ្សេងទៀតក្នុងឯកសណ្ឋានផ្សេង និងកាន់អាវុធធន់ធ្ងន់ បានមកដល់។ ប្រភពទីបួនដែលរស់នៅភូមិស្វាយឃ្លាំងដែរ នៅក្នុងអំឡុងពេលវាយប្រហារបង្ក្រាបនោះ បានបញ្ជាក់ថា មានការវាយប្រហារបួនមុខសញ្ញា រួមមាន កងកម្លាំងស្រុកក្រូចឆ្មារសម្រុកចូលមកជាកម្លាំងទប់ស្កាត់នៅខាងលិចស្វាយឃ្លាំង ហើយកងកម្លាំងរបស់កងវរសេនាធំ តំបន់ ២ មកពីព្រំដែន បានវាយប្រហារពីខាងកើត ខាងត្បូង និងវាយប្រហារតាមកាណូតនៅលើទន្លេមេគង្គ។ ប្រភពនេះបានបញ្ជាក់ថា យោធាទាំងនោះបានវាយប្រហារភូមិនេះដោយប្រើប្រាស់កាំភ្លើងត្បាល់ ៦០ និង ៨០ មីលីម៉ែត្រ ហើយខណៈនោះដែរក៏បានបាញ់អ្នកភូមិ ដោយ

---

[74] ឯកសារ **E347.3**, របាយការណ៍ HRW ទំព័រ ១៥ និង ១៩ (ជើងទំព័រត្រូវបានលុបចេញ)។

> ប្រើប្រាស់កាំភ្លើងវែង និងគ្រាប់បែករ៉ុកកែត សម្លាប់អ្នកភូមិអស់រាប់រយនាក់។ គាត់និយាយទៀតថា យោធាតំបន់ចូលមកតាមចម្ការកៅស៊ូ ឬក៏ទៅខាងត្បូងក្រូចឆ្មារ[75]។

28. មេធាវីការពារក្តី កត់សម្គាល់ថា ព័ត៌មានរបស់ HRW ត្រូវបានបញ្ជាក់តាមរយៈ សូ សីម៉ិច (ជាសាក្សីម្នាក់បន្ថែមទៀតដែលបានស្នើនៅផ្នែក គ ខាងក្រោមនេះ) ដែលបញ្ជាក់ថា កងវរសេនាតូច ៥៥ បានទទួលបញ្ជាបង្ក្រាបការបះបោររបស់ជនជាតិចាម ហើយបានរៀបរាប់ពីការទទួលខុសត្រូវរបស់លោក ហ៊ុន សែន នៅក្នុងសេនាធិការកងវរសេនាធំ តំបន់ ២១ នៅពេលនោះ[76]។ បន្ថែមពីលើនេះទៀត ព័ត៌មាននេះគឺស្របគ្នាជាមួយនឹងសក្ខីកម្មរបស់អ្នកភូមិជនជាតិចាមពីរនាក់មកពីស្វាយឃ្លាំង។ សុះ ពន់យ៉ាមីន បានផ្តល់សក្ខីកម្មនៅក្នុងសវនាការតុលាការថា កងកម្លាំងយោធាមាន "អត់ខ្វះ និយាយអីត្រឹមទូក ឧបករណ៍គេ សូម្បីតែម៉ារីន ក៏គេមានដែរ អ៊ីចឹងលទ្ធភាពគេ។ [...] អាកាបាញ់រះ មិនមែនសម្រាប់តែកាំភ្លើងតូចទេ ច្បាំងគ្នាហើយហ្នឹង អ៊ីចឹងសំខាន់សម្រាប់វាជាក់ស្តែង កាំភ្លើងធំហ្នឹងវាឮសូរស្តាប់អីមិនឮទេ។"[77]។ អ្នកភូមិជាមួយគាត់ឈ្មោះ ម៉ាន ស៊ើន បានប្រាប់ អ៊ីសា ឧស្មានថាកម្លាំងបន្ថែមដែលទើបតែមកដល់មានចំនួនកាន់តែច្រើនឡើងៗរាប់រយនាក់ស្លៀកពាក់ឯកសណ្ឋានខុសពីកងទ័ពស្រុក មានសាក់កាដូ និងមានកាំភ្លើងគ្រប់ធុន។ ខ្មែរក្រហមបាញ់ផ្តោងកាំភ្លើងធំ ជាមួយនឹងកាំភ្លើងធុនតូចសំដៅមកលើអ្នកបះបោរ[78]។

29. លោក ហ៊ុន សែន មានព័ត៌មានដែលមានភាពពាក់ព័ន្ធច្រើន ទាក់ទងនឹងការបង្ក្រាបការបះបោររបស់ជនជាតិចាមនៅស្វាយឃ្លាំង ជាពិសេសទាក់ទងនឹងតួនាទីរបស់យោធានកងវរសេនាតូច ៥៥ ដែលនៅក្រោមបញ្ជារបស់គាត់។ ក្នុងនាមជាប្រធានសេនាធិការប្រចាំកងវរសេនាតូច ៥៥ នៅពេលមានការបះបោររបស់ជនជាតិចាមនៅស្រុកក្រូចឆ្មារ លោក ហ៊ុន សែន ត្រូវតែបានដឹងឮដោយផ្ទាល់អំពីព្រឹត្តិការណ៍ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ ហើយច្បាស់ណាស់ គាត់អាចផ្តល់ព័ត៌មានសំខាន់ៗទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលចោទថាបានប្រព្រឹត្ត មកលើជនជាតិចាមនៅស្វាយឃ្លាំង។ ហេតុដូច្នេះ សក្ខីកម្មរបស់ លោក ហ៊ុន សែន នឹងជួយជ្រោមជ្រែងយ៉ាងខ្លាំងក្នុងការបញ្ជាក់ពីការពិតទាក់ទងនឹងព្រឹត្តិការណ៍ទាំងនោះ។

---

[75] ឯកសារ **E347.3**, របាយការណ៍ HRW ទំព័រ ២០ (ជើងទំព័រត្រូវបានលប់ចេញ)។

[76] សូមមើល កថាខណ្ឌ ២២ ខាងក្រោម។

[77] ប្រតិចារឹក ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥ (សុះ ពន់យ៉ាមីន ឯកសារ **E1/343.1**) ទំព័រ ៩៥ បន្ទាត់ ២ និង ៦-៧។

[78] ឯកសារ **E3/2653**, អ៊ីសា ឧស្មាន, *The Cham Rebellion: Survivors' Stories from the Villages*, ERN KH 00904323 (កិច្ចសម្ភាសន៍ជាមួយ ម៉ាន ស៊ើន)។

30. ទោះបីជា លោក ហ៊ុន សែន ធ្លាប់ត្រូវបានស្នើឱ្យធ្វើជាសាក្សីម្នាក់របស់មេធាវីការពារក្តី ហើយការស្នើនោះត្រូវបានច្រានចោលក៏ដោយ ក៏ការចេញរបាយការណ៍របស់ HRW នៅខែ មករា ឆ្នាំ ២០១៥ បានកែប្រែភ័ស្តុតាងរបស់លោក ហ៊ុន សែន ទៅជាភ័ស្តុតាងដ៏សំខាន់ដែលត្រូវតែស្តាប់នៅក្នុងសវនាការ[79]។ របាយការណ៍នេះបានចេញផ្សាយបន្ទាប់ពីសវនាការបានចាប់ផ្តើមអស់រយៈពេលជាយូរមកហើយ។ ដូច្នេះ លក្ខខណ្ឌតម្រូវនៃវិធាន ៨៧ (៤) ត្រូវបានបំពេញហើយ។ ក្នុងករណីណាក៏ដោយ ផលប្រយោជន៍យុត្តិធម៌ តម្រូវថា សក្ខីកម្មរបស់លោក ហ៊ុន សែន ត្រូវតែស្តាប់នៅក្នុងសវនាការ។ លោក ហ៊ុន សែន អាចមានលទ្ធភាពបង្ហាញអត្តសញ្ញាណរបស់ចារីដែលត្រូវបានចោទថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងជនជាតិចាមនៅស្វាយឃ្លាំង និងអាចនៅភូមិកោះផល និងទ្រាផងដែរ។ សក្ខីកម្មតែមួយគត់ដែលអង្គជំនុំជម្រះបានស្តាប់នៅក្នុងសវនាការ ទាក់ទងនឹងព្រឹត្តិការណ៍ទាំងនោះ គឺជាសក្ខីកម្មរបស់ សុះ ពន់យ៉ាមីន ដែលបង្ហាញថាមិនអាចបង្ហាញអត្តសញ្ញាណបែបនោះបានឡើយ[80]។ ប្រសិនបើអង្គជំនុំជម្រះមានបំណងបង្ហាញអត្តសញ្ញាណជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលអាចកើតឡើងនៅកោះផល ស្វាយឃ្លាំង និងទ្រា និងបញ្ជាក់ពីការពិតអំពីព្រឹត្តិការណ៍ទាំងនោះ និងបន្ទាប់មកដើម្បីជាប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះគួរតែស្វះស្វែងរកសក្ខីកម្មពីលោក ហ៊ុន សែន ដែលមានភ័ស្តុតាងសំខាន់ពាក់ព័ន្ធនឹងរឿងនេះ។

## គ. សាក្សីបន្ថែម៖ សូ សីម៉ុច (អតីតយោធាកងវរសេនាតូច ៥៥ ភូមិភាគបូព៌ា)

31. សូ សីម៉ុច គឺជានិរសារម្នាក់នៅកងវរសេនាតូច ៥៥ តំបន់ ២១ ភូមិភាគបូព៌ា ប្រចាំការនៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។ នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់គាត់ សូ សីម៉ុច រៀបរាប់អំពីរចនាសម្ព័ន្ធបញ្ជាការនៅតំបន់ ២១ នៅឆ្នាំ ១៩៧៥។ គាត់បញ្ជាក់ថា សុខ សាធ មេបញ្ជាការកងវរសេនាតូច ៥៥ បានបញ្ជូនយោធាទៅបង្ក្រាបការបះបោរនៅកោះផល ស្វាយឃ្លាំង

[79] អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្តើមនៅក្នុងខែ មិថុនា ឆ្នាំ ២០១១៖ សូមមើល ឯកសារ **E307/1**, 'សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧ ឯកសារ) (៤)E307 (សេចក្តីជូនដំណឹងនិងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភ័ស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ) E305/3(', ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ២ឯក ,សារ **E307/1/2**, 'សេចក្តីសម្រេចលើសំណើសុំរួមឲ្យសម្រេច *សាជាថ្មីឡើងវិញ*លើការអនុវត្តវិធាន ៨៧ក្នុងនៃវិធានផ្ទៃ (៤)', ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

[80] សូមមើល ប្រតិចារឹក ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥ (ឯកសារ **E1/344.1**) ទំព័រ ២០ បន្ទាត់ ២៤ ដល់ទំព័រ ២១ បន្ទាត់ ១ និងទំព័រ ២២ បន្ទាត់ ១-៤។

និងទ្រា[81]។ គាត់ក៏រៀបរាប់អំពីតួនាទីរបស់លោក ហ៊ុន សែន នៅតំបន់ ២១ ក្នុងនាមជាសមាជិកម្នាក់នៅក្នុងកងស៊ើបការណ៍កងវរសេនាតូច ៥៥ បន្ទាប់មកតួនាទីជាប្រធានសេនាធិការកងវរសេនាការតំបន់ នៅក្រោយខែ មេសា ឆ្នាំ ១៩៧៥[82]។

32. សូ សីម៉ិច មានព័ត៌មានពាក់ព័ន្ធទាក់ទងនឹងការបង្ក្រាបយ៉ាងព្រៃផ្សៃមកលើការបះបោររបស់ជនជាតិចាមនៅកោះផល ស្វាយឃ្លាំង និងទ្រា ជាពិសេសទាក់ទងនឹងការចូលរួមរបស់កងវរសេនាតូច ៥៥ តំបន់ ២១។ សក្ខីកម្មរបស់គាត់ នឹងជួយបញ្ជាក់ពីការពិតទាក់ទងនឹងព្រឹត្តិការណ៍ទាំងនោះ។ ទោះបីជាសក្ខីកម្មរបស់ សូ សីម៉ិច អាចទទួលបាននៅមុនពេលបើកសវនាការក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង គួរតែស្តាប់សក្ខីកម្មរបស់គាត់ ដើម្បីជាប្រយោជន៍យុត្តិធម៌។ សូ សីម៉ិច អាចមានលទ្ធភាពបង្ហាញអត្តសញ្ញាណចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលចោទថាបានប្រព្រឹត្តមកលើជនជាតិនៅកោះផល ស្វាយឃ្លាំង និងទ្រា។ ហេតុដូច្នេះ សក្ខីកម្មរបស់ សូ សីម៉ិច នឹងជួយអង្គជំនុំជម្រះ បង្ហាញអត្តសញ្ញាណជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែល ចោទថាបានប្រព្រឹត្តនៅកោះផល ស្វាយឃ្លាំង និងទ្រា។

## ឃ. សាក្សីបន្ថែម៖ [redacted] (កូនប្រុសរបស់ [redacted] និងលេខាភូមិភាគតំបន់ ២១ [redacted])

33. [redacted] គឺជាកូនប្រុសរបស់អតីត [redacted] គាត់ធ្វើជានិរសារឲ្យឪពុករបស់គាត់រហូតក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[83]។ [redacted] លើកឡើងអំពីការបះបោររបស់ជនជាតិចាមនៅកោះផល ដោយគាត់កត់សម្គាល់ថា "បន្ទាប់ពីមានការបោសសម្អាតនៅកោះផល គេមិនសូវទុកចិត្ត[ជនជាតិចាម]" ហើយគាត់ត្រូវតែ "មានការប្រុងប្រយ័ត្ននៅពេលដើរកាត់ភូមិចាម" ដោយបន្ថែមទៀតថា "ក្រោយពីការបោសសម្អាតនៅតំបន់នោះហើយ គេបានជម្លៀសប្រជាជនទាំងអស់នៅកន្លែងនោះ មិនថា ជនជាតិចាម ឬខ្មែរទេ"[84]។ [redacted] ក៏ចងចាំពីការសន្ទនាចុងក្រោយរបស់គាត់ជាមួយឪពុករបស់គាត់នៅពេលមួយក្នុងឆ្នាំ ១៩៧៨ ដែលតាមសេចក្តីរាយការណ៍បានប្រាប់គាត់ថា "កុំនិយាយអំពីរឿងចាស់មុន(នៅតំបន់

---

[81] ឯកសារ **E3/5261**, កំណត់ហេតុស្តាប់ចម្លើយសាក្សី សូ ស៊ីម៉ិច, ERN KH 00250943។

[82] ឯកសារ **E3/5261**, កំណត់ហេតុស្តាប់ចម្លើយសាក្សី សូ ស៊ីម៉ិច, ERN KH 00250943 និង 00250944។

[83] ឯកសារ **E3/5531**, 'កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩, ERN 00425885។

[84] ឯកសារ **E3/5531**, កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted], ERN KH 00418510-11។

២១)" ហើយបានណែនាំគាត់ "ឱ្យប្រាប់អតីតកូនចៅរបស់គាត់មុនៗថា កុំឱ្យនិយាយអ្វីទាំងអស់ *ធ្វើមិនដឹងមិនឮអំពីតំបន់ ២១*"[85]។

34. [redacted] មានភស្តុតាងពាក់ព័ន្ធទាក់ងនឹងការប្រព្រឹត្តមកលើជនជាតិចាមបន្ទាប់ពីមានការបះបោរនៅកោះផល។ [redacted]។

35. ទោះបីជា សក្ខីកម្មរបស់ [redacted] អាចទទួលបាននៅមុនពេលបើកសវនាការក៏ដោយ ក៏ អង្គជំនុំជម្រះសាលាដំបូង គួរតែស្តាប់សក្ខីកម្មរបស់គាត់ ដើម្បីជាប្រយោជន៍យុត្តិធម៌។ [redacted] មានភស្តុតាងដោះបន្ទុកដែលបញ្ជាក់ថា ប្រជាជននៅក្រូចឆ្មារ មិនថាជាជនជាតិចាម ឬខ្មែរ ទេ គឺមិនមែនជាគោលដៅដោយសារមូលហេតុជាតិសាសន៍ ជាតិពន្ធុ ឬសាសនាឡើយ ប៉ុន្តែដោយសារពួកគាត់បានចូលរួមក្នុងការបះបោរប្រដាប់អាវុធប្រឆាំងនឹងអាជ្ញាធរមូលដ្ឋាន។ បន្ថែមពីលើនេះទៀត [redacted] ហាក់ដូចជាដឹងអំពីព័ត៌មានដែលមានលក្ខណៈរសើបខ្លាំងទាក់ទងនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅតំបន់ ២១។ ខណៈដែលមានការលំបាកក្នុងការសន្និដ្ឋានអំពីលក្ខណៈនៃព័ត៌មានបែបនេះ ប៉ុន្តែ អង្គហេតុដែលថា កម្មាភិបាលជាន់ខ្ពស់បំផុតនៅក្នុងតំបន់ មានការប្រុងប្រយ័ត្នដើម្បីរក្សាការសម្ងាត់នោះ បង្ហាញថាព័ត៌មាននេះមានការពាក់ព័ន្ធសម្រាប់រឿងក្តីនេះ។

## ង. សាក្សីបន្ថែម៖ កា ដេវ (កូនស្រីរបស់ សោ ភឹម និងយាយ ការ៉ូ )

36. នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ សារព័ត៌មាន *រស្មីកម្ពុជា* ដែលចេញផ្សាយប្រចាំថ្ងៃ បានចុះផ្សាយអត្ថបទមួយជាភាសាខ្មែររបស់ ឡុង ដានី[86] ដែលជាអ្នកស៊ើបអង្កេត និង អ្នកស្រាវជ្រាវនៅម

[85] ឯក [redacted], កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted], ERN KH 00418514(គូសបញ្ជាក់បន្ថែម)។

[86] ឡុង ដានី, 'រូបថតគ្រួសារ សោ ភឹម ប្រធានភូមិភាគបូព៌ាក្នុងរបបខ្មែរក្រហម', សារព័ត៌មានរស្មីកម្ពុជា ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥។

ជ្ឈមណ្ឌលឯកសារកម្ពុជា។ អត្ថបទនេះដកស្រង់បទសម្ភាសន៍របស់ ឡុង ដានី ជាមួយ កា ដេវ ដែលជាកូនស្រីរបស់ សោ ភឹម និងជាអ្នកដែលនៅមានជីវិតតែម្នាក់កត់នៅក្នុងគ្រួសាររបស់ សោ ភឹម ហើយកំពុងរស់នៅក្នុងភូមិដាច់ស្រយាលមួយស្ថិតនៅជាប់ព្រំដែនកម្ពុជា-ថៃ។ នៅក្នុងអត្ថបទនេះ កា ដេវ បានផ្តល់ព័ត៌មានយ៉ាងលម្អិតអំពីអាជីពនយោបាយរបស់ សោ ភឹម (ដោយបង្ហាញថា សោម ភឹម គឺជា[បងធំ]ទី ៤ នៅក្នុង ក.ប.ក) ព័ត៌មានលម្អិតអំពីគ្រួសាររបស់ សោ ភឹម និងការធ្វើអត្តឃាតរបស់គាត់។ កា ដេវ ក៏បានផ្តល់ព័ត៌មានដែលគាត់បានឃើញផ្ទាល់ភ្នែកអំពីការចាប់ខ្លួននៅឆ្នាំ ១៩៧៨ នៅភូមិភាគពាយ័ព្យ គឺការចាប់ខ្លួនបងស្រីរបស់គាត់ឈ្មោះ ស៊ី និងប្តីរបស់ ស៊ី ឈ្មោះ ជាល ដែលជាកូនប្រុសរបស់ រស់ ញឹម និងជាសមាជិកតំបន់៥ក្នុងភូមិភាគពាយ័ព្យ ដែលត្រពាំងថ្មនៅទីនោះ និងអ្នកដែលចូលរួមបះបោរប្រឆាំងនឹង បកក។

37. កា ដេវ អាចមានលទ្ធភាពបញ្ជាក់ពីការអះអាងរបស់លោក [redacted] នៅក្នុងបទសម្ភាសន៍មួយជាមួយ Ben Kiernan ដែលថា ទាក់ទងនឹងការបង្ក្រាបការបះបោររបស់ជនជាតិចាម "គឺ [សោ ភឹម] ជាអ្នកចុះហត្ថលេខាលើបញ្ជាឲ្យ ភ្លូង ទៅសម្លាប់ជនជាតិចាមនៅទ្រា នៅឆ្នាំ ១៩៧៥"។ គាត់ "កាច" ហើយ "កិច្ចការរបស់ជនជាតិចាម ម៉ូស្លីមនៅតំបន់តាមបណ្តោយទន្លេមេគង្គជុំវិញទ្រា និងកន្លែងផ្សេងទៀត គឺជាការងារបញ្ជាពី សោ ភឹម។ គាត់ពិតជាមនុស្សព្រៃផ្សៃម្នាក់"[87]។ កា ដេវ មានលទ្ធភាពផ្តល់ព័ត៌មានដែលគាត់បានឃើញផ្ទាល់ភ្នែកអំពីការចាប់ខ្លួនកូនប្រុសរបស់ រស់ ញឹម និងកូនស្រីរបស់ សោ ភឹម នៅភូមិភាគពាយ័ព្យ នៅឆ្នាំ១៩៧៨ ហើយអាចមានភស្តុតាងថែមទៀតសម្រាប់ការបញ្ជាក់ពីការអះអាងរបស់មេធាវីការពារក្តី ដែលថា ប.ក.ក មានបញ្ហារុកគួន ដោយសារការបាក់បែកផ្ទៃក្នុង រាប់បញ្ចូលទាំងការបះបោរនៅបូព៌ា និងភូមិភាគពាយ័ព្យផងដែរ ដោយរាប់បញ្ចូលទាំង សោ ភឹម និង រស់ ញឹម នឹងជួបគ្នានៅភូមិភាគពាយ័ព្យក្នុងលេសថា សោ ភឹម កំពុងសួរសុខទុក្ខកូនរបស់ខ្លួន[88]។ គាត់ក៏អាចមានលទ្ធភាពផ្តល់ពន្លឺអំពីតួនាទីរបស់ សោ ភឹម នៅភូមិភាគបូព៌ា ព្រមទាំងព្រឹត្តិការណ៍នានា រចនាសម្ព័ន្ធ សេចក្តីសម្រេច និងគោលនយោបាយនៅក្នុងភូមិភាគនេះផងដែរ។

38. មេធាវីការពារក្តី បានដឹងអំពីវត្តមានរបស់ កា ដេវ នៅពេលមានការចុះផ្សាយរបស់សារព័ត៌មាន

---

[87] ឯកសារ **E3/1593**, Kiernan, *The Pol Pot Regime*, [redacted]។

[88] សូមមើល **F2/8**, សំណើលើកទីប្រាំមួយសុំភស្តុតាងបន្ថែម កថាខណ្ឌ ៣៣ ដល់៣៤។

*រស្មីកម្ពុជា* ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥។ ទោះបីជាថា តាមលក្ខណៈបច្ចេកទេស សក្ខីកម្មរបស់ កា ដេវ អាចទទួលបាននៅមុនពេលបើកសវនាការក៏ដោយ ក៏ មេធាវីការពារក្តី មិនបានដឹងអំពីវត្តមានរបស់គាត់ ហើយទំនងដែរថា សហចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញានៅក្នុងសំណុំរឿង ០០២ ០០៣ និង ០០៤ ក៏មិនបានដឹងអំពីវត្តមានរបស់គាត់ដែរ ហើយវត្តមានរបស់គាត់ ក៏ប្រហែលជាមិនអាចរកឃើញដែរទោះបីជាមានការយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវក៏ដោយ ពីព្រោះថា មេធាវីការពារក្តី ត្រូវហាមឃាត់មិនឲ្យបំពេញកិច្ចស៊ើបសួរដោយឯករាជ្យទេនៅពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ ជាលទ្ធផល ការខកខានមិនបានរកឲ្យឃើញពីវត្តមានរបស់ កា ដេវ ឲ្យបានទាន់ពេលវេលានោះ មិនអាចថាដោយសារតែមានការធ្វេសប្រហែសពីសំណាក់មេធាវីការពារក្តីទេ។ ហេតុដូច្នេះ សក្ខីកម្មរបស់ កា ដេវ អាចអនុញ្ញាតឲ្យទទួលយក អនុលោមតាមវិធានផ្ទៃក្នុង ៨៧(៤)[89]។

## V. សំណើ

39. មេធាវីការពារក្តី ស្នើសុំ អង្គជំនុំជម្រះសាលាដំបូង កោះហៅ៖ (ក)សាក្សីដែលបានស្នើសុំរួចហើយ គឺលោក [redacted] និង [redacted] ឲ្យបានឆាប់រហ័ស និង (ខ) សាក្សីថ្មី គឺលោក ហ៊ុន សែន, ស្វូ សីម៉ុច , [redacted] និង កា ដេវ ដើម្បីផ្តល់សក្ខីកម្មនៅក្នុងសវនាការស្តីពីការប្រព្រឹត្តិមកលើជនជាតិចាម។

**សហមេធាវីការពារក្តីលោក នួន ជា**

**ស៊ុន អរុណ** Victor KOPPE

[89] សូមមើល **F2/5** “សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់នួន ជាសុំកោះហៅសាក្សីសម្រាប់បណ្តឹងសាទុក្ខ” ២៩ ខសភា ២០១៥ កថាខណ្ឌ ១៩។